# សិល្បៈតម្បាញសូត្រខ្មែរ

# ពិតាន



រៀបរៀងដោយ នាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម

ឆ្នាំ ២០១៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌

នាយកដ្ឋានសិល្បៈសូនរូប និង សិល្បៈសិប្បកម្ម


សៀវភៅ

# សិល្បៈតម្បាញសូត្រខ្មែរ

# ពិតាន


រក្សាសិទ្ធិ ឆ្នាំ ២០១៨

## *វិធីធ្វើសំពត់ហូល*

*វិធីធ្វើសំពត់ហូលនេះ មានលក្ខណៈពិបាកធ្វើណាស់ និងមានប្រើរយៈពេលយ៉ាងយូរ។ បើមនុស្សគ្មានការព្យាយាមស្វិតស្វាញទេ មិនអាចធ្វើសំពត់ហូលបានឡើយ។ សូមបញ្ជាក់ថា មុននឹងបានសូត្រមកត្បាញជាហូល គេត្រូវចិញ្ចឹមដង្កូវនាង សម្រាប់ខារយកសូត្រសិន។*

### I. *វិធីចិញ្ចឹមដង្កូវនាង*

*មុននឹងបានដង្កូវនាងមកស្រាវយកសូត្រ គេត្រូវរៀបចំវិធីចិញ្ចឹមដង្កូវនាងឲ្យបានល្អប្រសើរ ទើបការស្រាវយកសូត្រពីសម្បុកដង្កូវនាងបានផលច្រើនដែរ។ ខ្ញុំសូមដកស្រង់និងកែសម្រួលត្រង់ចំណុចខ្លះៗចេញពីសៀវភៅ «ការដាំមន និងការចិញ្ចឹមដង្កូវនាង» របស់សមាគមនារីបដិវត្តកម្ពុជា និងតាមការសាកសួរអ្នកចិញ្ចឹមដង្កូវនាងផ្ទាល់ ពីចំណុចខ្លះៗនៃការចិញ្ចឹមដង្កូវនាង មកសរសេរគ្រាន់បានជាគោលគំនិត ឲ្យបានដឹងខ្លះៗប៉ុននោះមិនមែនជាលក្ខណៈត្រឹមត្រូវតាមវិធីចិញ្ចឹមដង្កូវនាងទាំងអស់ទេ។ បើចង់ដឹងច្បាស់ សូមមើលសៀវភៅ «ការដាំមន និងការចិញ្ចឹមដង្កូវនាង» ផងចុះ។*

*សូមបញ្ជាក់ថា ការស្រាវយកសូត្រពីសម្បុកដង្កូវនាងបានផលច្រើនដោយសារៈ*

*១. ការដាំមកធ្វើជាចំណីដង្កូវនាង តាមវិធីដាំត្រឹមត្រូវល្អ*

*២. ការធ្វើផ្ទះចិញ្ចឹមដង្កូវនាងបានត្រឹមត្រូវល្អ*

*៣. ឲ្យចំណីដង្កូវនាងស៊ីបានសមស្រប*

*<u>ក. វិធីដាំដើមមន</u>*

*ពាក្យថា «មន» ជាឈ្មោះឈើដំណាំមួយប្រភេទ សម្រាប់ដាំយកស្លឹកឲ្យដង្កូវនាងស៊ីជាចំណីៈ*

- *ក្នុងវចនានុក្រមខ្មែរ ជ.ណា ជោតញ្ញាណោទំព័រ៨៥០ ព្រះអង្គបានបញ្ជាក់ថាមន ១. ន. ឈ្មោះឈើដំណាំមួយប្រភេទ គេដាំយកស្លឹកធ្វើជាចំណីដង្កូវនាងធ្វើសូត្រៈ មនមាន០២ប្រភេទគឺ មនតូត មានដើមតូច ស្លឹកតូច, មនធំ មានដើមធំ ស្លឹកធំ ដាំតែម្តងរស់នៅបានយូរឆ្នាំ។*
- *តាមពត៌មានពីលោក វង់ សារឿន នៅស្រុកកោះស្លា អនុខេត្តស្រការនោគ (កំពត) សព្វថ្ងៃគាត់ធ្វើការនៅអង្គការសិទ្ធិមនុស្ស គាត់បានបញ្ជាក់ថា មនមានបីប្រភេទគឺៈ*

១. មនបាយ មនមានស្លឹកទន់ ស្លឹកតូច តែមានស្លឹកញឹក សម្រាប់យកស្លឹកហាន់ឲ្យដង្កូវនាងនៅតូចៗ ស៊ីជាចំណី។ មននេះមានផ្លែប្រហាក់ប្រហែលនឹងផ្លែព្រីងបាយ តែមានរាងកន្ទួលតូចៗ។ ផ្លែមនរសជាតិជូរអែមៗ តែដល់ទុំជាំសម្បុកមានរសជាតិផ្អែមត្រជាក់។

២. មនឈើ មនមានស្លឹករឹងបន្តិចជាងមនបាយ ផ្លែមានរាងវែងដូចផ្លែជីប្លី មានកន្ទួលធំៗជាងមនបាយ ពេលទុំមានរសជាតិជូរអែមៗ លុះដល់ទុំជាំសម្បុករសជាតិផ្អែមត្រជាក់។

៣. មនសៀម មានស្លឹក និងផ្លែប្រហាក់ប្រហែលគ្នានឹងមន ឈើដែរ សម្រាប់បេះយកស្លឹកមនធ្វើជាចំណីឲ្យដង្កូវនាងធំៗស៊ី។

កាលបើដើមមនមានអាយុបាន០៨ខែហើយ គេត្រូវជ្រើសរើសកាត់យកមែកណាដែលមានការលូតលាស់ល្អជាងគេនោះ. ជាកង់ៗ។ គេយកមែកដែលល្អហើយនោះទៅកប់ដាំនឹងដីដែលគេបានភ្ជួររាស់ត្រឹមត្រូវ តាមក្បួនហើយនោះ។ គេដាំមននៅដើមរដូវភ្លៀង។ គេត្រូវជ្រើសយកប្រភេទដើមមន ដែលផ្តល់ទិន្នផលខ្ពស់ទៅដាំ។ គេត្រូវកប់ក្នុងដីជម្រៅប្រហែល១៥ស.ម។ គេត្រូវទុកឲ្យសល់ថ្នាំងពន្លក០១យ៉ាងតិច នៅលើដី។ គេត្រូវជៀសវាងការដាំបញ្ច្រាសថ្នាំង។ ការដាំចម្ងាយពីគ្នាទទឹងរង៦០ស.ម បណ្តោយរង២៥ស.ម។

<u>ខ. ផ្ទះចិញ្ចឹមដង្កូវនាង</u>

ផ្ទះចិញ្ចឹមដង្កូវនាង ត្រូវមានលក្ខណៈល្អប្រសើរ

១. ចិញ្ចឹមដង្កូវនាង សម្រាប់ឲ្យមានខ្យល់អាកាសចេញចូលបានគ្រប់គ្រាន់។

២. មានសម្ភារៈ សម្រាប់បង្កជាតុអាកាសសមស្រប អាចជួយកម្ចាត់មេរោគប្រកបដោយប្រសិទ្ធភាព។

៣. មានពិតានខ្ពស់ រហូតដល់០២ម៉ែត្រកន្លះ ដើម្បីរក្សាសីតុណ្ហភាពក្នុងផ្ទះឲ្យនៅនឹងល្អ។

៤. ខ្យល់អាកាសចេញចូលល្អ ដើម្បីសម្របសម្រួលសីតុណ្ហភាព និងភាពសើម។

<u>គ. បេះស្លឹកមន</u>

ក្រោយពីការដាំមនបាន០៦ខែ គេអាចបេះស្លឹកមនបានម្តង។ ក្រោយបន្ទាប់ពីការបេះស្លឹកលើកទី០១បានចំនួន០២ខែកន្លះ គេអាចបេះស្លឹកមនបានម្តងទៀត។ ការបេះស្លឹកនេះក្នុង០១ថ្ងៃបេះបាន០២ដង គឺនៅពេលព្រលឹមម្តង និងពេលល្ងាចម្តងទៀត។

*ឃ. មុនពេលបេះស្លឹក*

*មនុពេលបេះស្លឹកមនប្រហែលមួយអាទិត្យ គេត្រូវកាត់ត្រួយមនចំកន្វែងណាដែលត្រូវកាត់ស្លឹកទាំងមែកឲ្យដង្កូវនាងស៊ី។ ស្លឹកទន់ ខ្ចីពេក ឬនៅចុងមែក គេមិនត្រូវកាត់ទៅឲ្យដង្កូវនាងស៊ីទេ ពីព្រោះវាមានជាតិទឹកច្រើនពេក។*

*ង. បេះស្លឹកទុកជា០៣ក្រុម*

*យើងឲ្យចំណីដង្កូវនាងស៊ី យើងត្រូវគិតតាមអាយុនៃដង្កូវនាង ទើបរាងកាយដង្កូវនាងមានការលូតលាស់ល្អ។ ដូចនេះ កាលបើយើងបេះស្លឹកមន យើងត្រូវបេះទុកជា០៣ក្រុមដើម្បីយកស្លឹកមនតាមក្រុមនេះ ឲ្យដង្កូវនាងស៊ីតាមអាយុវា។*

*១. កម្រិតដំបូង យើងត្រូវយកស្លឹកមនក្រុមទី០១ គឺស្លឹកមនទន់ ខ្ចី ឲ្យដង្កូវនាងតូចល្អិតស៊ី។*

*២. កម្រិតទី០២ យើងត្រូវយកស្លឹកមនក្រុមទី០២ គឺស្លឹកមនដែលមានពណ៌បៃតងចាស់ឲ្យដង្កូវនាងធំបន្តិចស៊ី។*

*៣. កម្រិតទី០៣ យើងត្រូវយកស្លឹកមនក្រុមទី០៣ គឺស្លឹកមនកាត់តែចាស់ឲ្យដង្កូវនាងធំស៊ី។*

*សូមបញ្ជាក់ថា ស្លឹកមនក្រុមទី០១ ត្រូវហាន់ឲ្យល្អិត, ស្លឹកមនក្រុមទី០២ ត្រូវហាន់ឲ្យធ្វើសជាងក្រុមទី០១, ស្លឹកមនក្រុមទី០៣ ត្រូវហាន់ឲ្យធ្វើសជាងក្រុមទី០២។*

*ច. ការពារដើមមន*

*យើងត្រូវយកចិត្តទុកដាក់ បាញ់ថ្នាំការពារដើមមនឲ្យបានល្អ។ ក្រោយពេលបាញ់ថ្នាំបំផ្លាញសត្វល្អិតចំនួន១០ ឬ១៥ថ្ងៃ ទើបគេបេះយកស្លឹកមនឲ្យដង្កូវនាងស៊ី។*

*ឆ. ដង្កូវនាងនៅតូច*

*កាលបើដង្កូវនាងនៅតូចល្អិត ដែលទើបលើកក្បាលៗ វាស៊ីស្លឹកមនយឺត។ ដូចនេះការឲ្យស្លឹកមនដង្កូវនាងស៊ីលើកដំបូង គេត្រូវឲ្យស្លឹកមនជាចំណីតិច ហើយគួររើសយកស្លឹកខ្ចី និងហាន់ឲ្យតូចៗ។*

*ជ. កន្លែងចិញ្ចឹម*

*យើងចិញ្ចឹមដង្កូវនាង មិនត្រូវដាក់ឲ្យនៅក្នុងកន្លែងចង្អៀតពេកទេ វាអាចធ្វើឲ្យដង្កូវនាងស៊ីមិនគ្រប់គ្រាន់ ហើយមានការលូតលាស់មិនស្មើគ្នា ឬវាអាចធ្វើឲ្យដង្កូវនាងមានជម្ងឺយ៉ាងងាយ ហើយយើងបានទទួលផលតិច។*

*ឈ. ការវិវត្ត*

*បើយើងពិនិត្យតាមការវិវត្តនៃដង្កូវនាងឃើញថា ដង្កូវនាងកើតអំពីមេអំបៅ។ កាលបើមេអំបៅពងដាក់សម្បុក ពងនោះត្រូវញាស់ចេញជាកូនដង្កូវនាងតូចល្អិច ជាដង្កូវនាងតាមលំដាប់ ជាដង្កូវនាងកសូត្រ ជាដក់ដឿ ជាមេអំបៅ។*

*ញ. ដង្កូវនាងកសូត្រ*

*ការចិញ្ចឹមដង្កូវនាងដល់កំណាត់នៃសត្វដង្កូវនាងកសូត្រហើយ គេត្រូវៈ*

*១. ពីបុរាណ គេចាប់ដង្កូវនាងយកទៅឲ្យទុំលើមែកឈើ ដូចជាមែកសង្កែជាដើម។ ដង្កូវនាងចាប់កសម្បុកលើមែកឈនោះ។ លុះដល់០៥ឬ០៦ថ្ងៃ គេមើលសម្បុកដង្កូវនាងឡើងពណ៌ក្រហម គេបេះយកសម្បុកដង្កូវនាងនោះទៅស្ងោរស្រាវយកសូត្រ។*

*២. សម័យបច្ចុប្បន្ន គេចាប់យកដង្កូវនាងទៅដាក់ក្នុងចង្អេរ ដើម្បីឲ្យដង្កូវនាងរុំព័ទ្ធជាសម្បុកក្នុងចង្អេរនោះ។ លុះដល់ថ្ងៃទី០៥ គេបេះយកសម្បុកដង្កូវនាងទៅស្ងោរស្រាវយកសូត្រ។*

## II. *វិធីស្រាវយកសរសៃសូត្រ*

*យោងទៅលើចម្លើយរបស់លោកយាយ វ៉ាន់ រ៉េង  សព្វថ្ងៃនេះ លោកយាយកំពុងជួយឧបត្ថម្ភកូនត្បាញហូល នៅក្នុងព្រះបរមរាជវាំងជ្រុងទិសអាគ្នេយ៍។ លោកយាយមានប្រសាសន៍ថា កាលបើសម្បុកដង្កូវនាងនៅលើមែកឈើ មានពណ៌ក្រហម គេត្រូវរៀបចំប្រដាប់ប្រដា និងបេះសម្បុកដង្កូវនាងយកមកស្រាវយកសូត្រ។*

*ក. ឈើស្រាវ*

*ឈើ០៤កំណាត់ ០២កំណាត់វែងប្រហែល០១ម២០។ ឯពីរកំណាត់ទៀតខ្លីបន្តិច ប្រវែងប្រហែលជាង០១ម។ ចុងឈើវែង០១ ខ្លី០១ ត្រូវដាក់ភ្ជាប់គ្នា។ ឯចុងភ្ជាប់គ្នាទាំងពីរនេះ គេត្រូវយក*

*មកភ្ជាប់គ្នាទៀត ដោយឈើខ្វីប្រវែងប្រហែលជា០៣តឹក។ ឯគល់ឈើវែងទាំងពីរកំណាត់គេត្រូវភ្ជាប់គ្នាដោយកំណាត់ឈើខ្វីដែរ។ ឯគល់ឈើខ្វី គេត្រូវភ្ជាប់គ្នាដូចគល់ឈើវែងដែរ។ នៅត្រង់កំណាត់ឈើវែងពីរកំណាត់នោះ ប្រហែលជា០២ភាគ០៣ពីគល់ គេធ្វើក្ងៅរំអិលសម្រាប់ទាញសរសៃសូត្រ ឆ្វងកាត់វិលស្រួលស្រាវចេញពីសម្បុកដង្កូវនាង បញ្ចូលទៅក្នុងកុង។*

*ខ. វិធីស្រាវយកសូត្រ*

*គេយកឆ្នាំងធ្នល់ (ឆ្នាំងធំជាងឆ្នាំងធម្មតា តែតូចជាងថ្លាង) មកដាំទឹកឲ្យក្តៅល្មមបានគេយលឈើស្រាវមកដាក់គងលើមាត់ឆ្នាំង។ គេយកដង្កូវនាងទាំងសម្បុក មកបង់ក្នុងទឹកក្តៅឧណ្ហៗ នោះចំនួន០១ក្តាប់ម្តង។ គេយកឈើមូលរលោងមកកូរ សរសៃសូត្របែកចេញពីសម្បុកមករុំឈើមូលនោះ។ គេចាប់ស្រាវយកសរសៃសូត្រមកដាក់គងលើក្ងៅរំអិលទាញបញ្ចូលក្នុងកុង គឺដៃម្ខាងទប់សម្បុកដង្កូវនាង ឯដៃម្ខាងទៀតកាន់ដៃកុងរវៃឲ្យសរសៃសូត្ររុំព័ទ្ធជុំវិញកុង។*

*កាលបើការស្រាវយកសូត្រពីសម្បុកដង្កូវនាងអស់០១ក្តាប់ គេស្រង់យកសម្បុកចេញពីក្នុងឆ្នាំងឲ្យអស់ ទើបគេបង់បន្ថែម០១ក្តាប់ទៀត។ បើសរសៃសូត្ររុំព័ទ្ធកុងមានចំនួនល្មមហើយគេត្រូវដោះសូត្រចេញពីកុង ទ្វាក់ខ្វែងទុក០១កន្ទែង។ គេចាប់ធ្វើបែបនេះបន្តទៅទៀតរហូតដល់អស់ដង្កូវនាង។*

## III. *ជ្រើសរើសសរសៃសូត្រ*

*កាលបើការស្រាវយកសរសៃសូត្រ ចេញពីសម្បុកដង្កូវនាងបញ្ចូលទៅក្នុងកុងបានហើយ គេត្រូវយកសរសៃសូត្រដែលស្រាវបាននោះ ទៅដាក់បញ្ចូលក្នុងរផ្វង់ ដើម្បីទាញយកសរសៃសូត្រទៅដាក់បញ្ចូលទុកក្នុងអក្ស ជ្រើសរើសសរសៃសូត្រតាមតូច តាមធំ។*

*ក. រផ្វឹង*

*រផ្វឹងជាគ្រឿងតម្បាញមួយប្រភេទ ដែលគេធ្វើអំពីឈើ និងឫស្សី។ រផ្វឹងនេះមានឈើមេទទឹងដែលមានមុខកាត់០៤ជ្រុងទ្រវែង ប្រហែលជា ០,១២ម x ០,០៨ បណ្តោយប្រហែលជា ០,៥០ម ឬ ០,៦០ម។ មានឈើមេសំដូក សម្រាប់ទប់កុំឲ្យរលំ ដែលមានមុខកាត់ប្រហែល ០,០៨ម x ០,០៤ម, បណ្តោយប្រហែលជា ០,៤០ម សម្រាប់ដាក់ភ្ជាប់នឹងមេទទឹង។ នៅលើមេទទឹងចម្ងាយឃ្លាតពីគ្នា*

ប្រហែលជា ០,៤០ម គេដាប់ដំនាប់សម្រាប់ដាក់មេបញ្ឈរពីរ នៅចុងសងខាង។ នៅចុងខាងលើមេបញ្ឈរ គេខ្វៀល ឬដាប់សម្រាប់ដាក់ក្ងៅគោមរងើ្វង។ នៅចុងក្ងៅទាំងសងខាង គេលាក់បញ្ចូលបន្ទះឫស្សី០២ ឬ ០៣ ម្ខាង ធ្វើជាស្ទាប។ នៅចុងស្ទាបជាគូនឹងគ្នា គេចងខ្សែភ្ជាប់គ្នាពីចុងមួយផ្សេងទៀតសម្រាប់ទ្រសូត្រ។

រូបរងើ្វង គឺរូបដែលគេដាក់ជុំសរសៃសូត្រនៅខាងឆ្វេងដៃ លោកយាយ ហ៊ាង ណាន នៅខាងមុខ។

## ខ. អ័ក្ស

គ្រឿងប្រដាប់តម្បាញរបស់ខ្មែរមួយប្រភេទ ធ្វើអំពីឈើខ្លឹមមានកាំ០៨។ ប្រវែងកាំនីមួយៗប្រហែលជា០,១៥ម ទៅ០,២០ម មានរបារ, ខាងខ្នងរបារ មានសណ្ឋានមូល ខាងពោះមានសណ្ឋានសំប៉ែត ចុងរបារទាំងពីរខាង បញ្ចុះភ្ជាប់នឹងចុងកាំ មានក្ងៅធ្វើអំពីដែកមូលបង្វិលបាន មានជើងទ្រមាំ ជាប្រដាប់សម្រាប់ផាត់សូត្រ រៀបតាមសរសៃតូចធំរបស់ស្ត្រីខ្មែរ មានតាំងពីសម័យព្រេងនាយរហូតមក។

## គ. មុខងាររបស់រងើ្វង និងអ័ក្ស

រងើ្វង និងអ័ក្ស ជាគ្រឿងប្រដាប់តម្បាញដូចគ្នា តែរបស់ទាំងពីរនេះមានមុខងារផ្សេងខុសពីគ្នាៈ

### ១. មុខងាររបស់រងើ្វង

ពេលជ្រើសរើសសរសៃសូត្រតាមតូច តាមធំ តម្រៀបក្នុងអ័ក្សក្តី ពេលរវៃសូត្ររុំព័ទ្ធបំពង់ក្តី រុំព័ទ្ធខ្នារក្តី គេយកសូត្រដែលបានដោះចេញពីកុង មកពាក់នឹងស្ទាបរងើ្វង ទាញចេញបញ្ចូលព័ទ្ធអ័ក្ស ឬរវៃទាញរុំព័ទ្ធបំពង់ ឬខ្នារ។

### ២. មុខងាររបស់អ័ក្ស

គេទាញសរសៃសូត្រចេញពីរងើ្វង មករុំព័ទ្ធអ័ក្សតាមសរសៃតូច តាមសរសៃធំ តាមក្រុមដែលគេបានចែកជា០៤ ឬ០៥ក្រុម។ បើសូត្រធ្នារលេខ០១ គេផ្គាប់តដាក់លេខ០១, បើលេខ០២គេផ្គាប់តដាក់ក្រុមលេខ០២...។

សូមបញ្ជាក់

- ក្រុមទី០១ ជាក្រុមសូត្រធ្មារជាងគេ
- ក្រុមទី០២ ជាក្រុមសូត្រធំបន្ទាប់ពីក្រុមសូត្រទី០១
- ក្រុមទី០៣ ជាក្រុមសូត្រធំបន្ទាប់ពីក្រុមសូត្រទី០២
- ក្រុមទី០៤ ជាក្រុមសូត្រធំបន្ទាប់ពីក្រុមសូត្រទី០៣
- ក្រុមទី០៥ ជាក្រុមសូត្រធំជាងគេបង្អស់។ សូត្រក្រុមនេះ គេតែងហៅថាក្បាលសូត្រ ពីព្រោះសូត្រក្រុមនេះ មានភាពរមុិរម៉ង់ មិនរាបស្មើល្អ។

ដូច្នេះ បើគេរើសសូត្រដាក់តាមក្រុមបានហើយ គេត្រូវរៀបចំដុំសូត្រទុកដាក់តាមក្រុមកុំឲ្យច្រលំគ្នា ដើម្បីរៀបចំមុខងារឲ្យបានត្រឹមត្រូវ។

ក្រុមទី០១ សូត្រធ្មារជាងគេ

សូត្រក្រុមទី០១នេះ ជាក្រុមសូត្រមានសរសៃតូចធ្មារជាងគេ។ សូត្រក្រុមនេះ គេត្រូវគួបតែពីរសរសៃទេ សម្រាប់យកទៅធ្វើសរសៃអន្ទង (ស្រុកខ្លះហៅថាសរសៃផ្ទៃ)។

ក្រុមសូត្រទី០២, ០៣, ០៤

សូត្រក្រុមនេះ ជាក្រុមសូត្រសម្រាប់គួបយកទៅធ្វើជាសរសៃចាក់ទទឹងហូល។ គេត្រូវគួបឲ្យមានសរសៃធំជាងសរសៃធំជាងសរសៃអន្ទង។ ដូចនេះ បើក្រុមសូត្រដែលមានសរសៃធ្មារល្អិតគេត្រូវគួបឲ្យច្រើនសរសៃដើម្បីឲ្យហូលមានសាច់ក្រាស់ដូចជា៖

- ក្រុមទី០២ ជាក្រុមសូត្រមានសរសៃល្អិត គេត្រូវគួបសូត្រក្រុមនេះជា០៥ ឬ០៦សរសៃ។
- ក្រុមទី០៣ ជាក្រុមសូត្រដែលមានសរសៃធំជាងសូត្រក្រុមទី០២បន្តិច គេត្រូវគួបតែ ០៤ ឬ០៥សរសៃ។
- ក្រុមទី០៤ ជាក្រុមសូត្រដែលមានសរសៃធំជាងសូត្រក្រុមទី០៣បន្តិច គេត្រូវគួបតែ០៣ឬ០៤សរសៃប៉ុននោះ។

សូមបញ្ជាក់ថា ការគួបសរសៃសូត្រនេះ មិនមានលក្ខណៈច្បាស់លាស់ទេ ស្រេចទៅលើការស្រលាញ់នៃមនុស្សអ្នកធ្វើ។ អ្នកខ្លះ គេយកសូត្រក្រុមទី០២មួយសរសៃ ក្រុមទី០៣មួយសរសៃ ក្រុម

*ទី០៤មួយសរសៃ យកទៅគួបបញ្ចូលគ្នាតែម្តងក៏មាន។ អ្នកខ្លះ គេយកសូត្រក្រុមទី០២ចំនួយ០២ សរសៃ ក្រុមទី០៣មួយសរសៃ ក្រុមទី០៤មួយសរសៃ យកទៅគួបជាមួយគ្នាក៏បាន...។*

*ក្រុមសូត្រទី០៥*

*សូត្រក្រុមនេះ គេមិនយកទៅគួបទេ ពីព្រោះសូត្រក្រុមនេះមានសរសៃធំស្រាប់ផងមានភាពរមុរិរម៉ង់ផង គេគ្រាន់តែយកទៅរវៃវេញឲ្យខ្នាញ់ល្មមប៉ុននោះ។ សូត្រក្រុមនេះគេយកទៅធ្វើជាសរសៃចាក់ត្បាញសម្រាប់ឲ្យលោកយាយ លោកតា ស្លៀកនៅផ្ទះ។ សូត្រក្រុមនេះ ជាប់ជាង់សូត្រក្រុមដទៃឯទៀត។*

## IV. *ពិធីក្រនៀវ*

*គេយកសូត្រដែលគេបានជ្រើសរើសដាក់តាមក្រុមក្នុងអ័ក្សនោះ យកមកស្រាវដាក់បំពង់។*

### *ក. វិធីស្រាវសូត្រដាក់បំពង់*

*គេយកសូត្រដែលបានដោះចេញពីអ័ក្ស មកដាក់ក្នុងរង្វឹង។ គេយកបំពង់មកប្រហាកបញ្ចូលក្នុងឈើព្រលួតរហាត់ខារ។ គេយកសរសៃសូត្រមករុំព័ទ្ធបំពង់។ ដៃម្ខាងចាប់រវៃដៃរហាត់ ខារទាញសរសៃសូត្រចេញពីរង្វឹងមករុំព័ទ្ធបំពង់។ ឯដៃម្ខាងទៀតចាប់សរសៃសូត្រដែលរហាត់ខារ ខារទាញសរសៃសូត្រចេញពីរង្វឹង យកមករុំបំពង់ឲ្យបានល្អត្រឹមត្រូវ។ របៀបបុរាណ គេខារម្តងបានតែបំពង់មួយដូចរូបកុមារ កេង ពិសិដ្ឋ កំពុងតែខារបង្ហាញនេះ។*

*តែសម័យបច្ចុប្បន្ន គេអាចខារសរសៃសូត្របញ្ចូលបំពង់ម្តង។ បានរហូតដល់៤០បំពង់ ដូចរូបលោក លីវ កេង កំពុងតែជាន់ខារ និងនាង ស៊ាន យ៉េកទាង កំពុងតែដើររំដោះសរសៃសូត្រ។*

### *ខ. វិធីគួបសូត្រ*

*បើគេត្រូវការគួបសូត្រប៉ុន្មានសរសៃនោះ គេយកបំពង់សូត្រតាមចំនួនដែលខ្លួនត្រូវការគួប ឧទាហរណ៍ បើគេគួប០៥សរសៃ គេត្រូវយកបំពង់សូត្រ០៥មកបញ្ឈរនៅក្បែរនោះ។ គេចាប់យកសរសៃសូត្រ០១សរសៃម្តង។ មកបញ្ចូលក្នុងដែកបង្ក៉ង់ស្នួអន្ទង ឬដាក់ក្នុងចម្រឹងអ័ក្ស។ គេចាប់ទាញសរសៃសូត្រទាំងអស់ បញ្ចូលក្នុងប្រហោងដែករលោងមួយ។ គេយកដែលនោះទៅដាក់បង្កប់ក្នុងទឹក*

ចានៗ គេយកចុងទៅភ្ជាប់នឹងខ្នារ ដែលខ្ចូនបានស៊កក្នុងដែកព្រលួតៗ វេឡើងបញ្ចូលក្នុងខ្នារ រហូលដល់សរសៃសូត្ររុំព័ទ្ធពេញខ្នារៗ

*គ. វិធីក្រនៀវ*

កាលបើរវៃគួបបញ្ចូលពេញខ្នារហើយ គេចាប់ផ្ដាច់សរសៃសូត្រចេញពីបំពង់ៗ គេចាប់យកចុងសរសៃសូត្រគួបនោះ ទៅបញ្ចូលក្នុងប្រហោងដែក ទម្លាយយកចុងសរសៃសូត្រទៅចងភ្ជាប់នឹងកុងៗ ដៃម្ខាងចាប់កាន់ដៃរហាត់ បង្វិលឲ្យរិលយឺតល្មមៗ ឯដៃម្ខាងទៀតចាប់កាន់ដៃកុង បង្វិលទាញសរសៃសូត្របញ្ចូលក្នុងកុងឲ្យលឿនៗ

សូមបញ្ជាក់ថា

១. ដៃខាងរហាត់ចាប់បង្វិលយឺតៗ

២. ដៃខាងកុងចាប់បង្វិលឲ្យលឿន កុំឲ្យសរសៃសូត្រវេញខ្នាញ់ពេកៗ

៣. ដែកប្រហោងបញ្ចូលសរសៃសូត្រ ត្រូវដាក់នៅចំពីមុខដែកព្រលួតៗ

តែសម័យសព្វថ្ងៃនេះ គេគួបម្ដងបានច្រើនសរសៃៗ

V. ប្រមោកសូត្រ

គេដោះសូត្រចេញពីកុង គេយកសូត្រនោះទៅប្រមោកនឹងទឹកក្បុង ដើម្បីធ្វើឲ្យសរសៃសូត្រជ្រះសំបកៗ

*ក. វិធីធ្វើទឹកក្បុង*

១. វិធីធ្វើក្បុង

គេកាប់ដើមផ្ទីទុកឲ្យស្រពោន ឬនៅស្រស់ គេយកដើមផ្ទីទៅដុតឲ្យឆេះអស់ឬគេយកសំបកផ្ទៃគ ទៅដុតឲ្យឆេះអស់ដែរៗ កម្ទេចផេះដែលសល់ពីការដុតនោះ វាមានជាតិប្រៃ គេហៅថាកុងៗ ឯក្បុងដែលគេយកទៅប្រមោកសូត្របានល្អ គឺគេយកតែក្បុងផ្ទីស្រស់ៗ ឯក្បុងសំបកផ្ទៃគ គេមិនដែលយកទៅប្រមោកសូត្រឡើយ ពីព្រោះគេយកទៅប្រមោកមិនបានល្អដូចក្បុងផ្ទីទេៗ

២. វិធីលាយក្បុងនឹងទឹក

គេយកក្បុងទៅដាក់ក្នុងពាង ស្មានឲ្យល្មមនឹងចំនួនសូត្រ។ ការលាយយកទឹកក្បុងនេះ គេមិនឲ្យប្រៃពេកទេ ឬសាបពេកទេ។ គេយកទឹកភ្លៀងមកចាក់ក្នុងពាងក្បុងនោះហើយគេយកកំណាត់ឈើមកកូរឲ្យចូលគ្នាសព្វ។

៣. វិធីចម្រោះយកទឹកក្បុង

គេយកកូនល្អីល្មមទៅដាក់លើមាត់ពាង។ គេយកសំពត់ផាឌីប មកដាក់ក្រាលក្នុងកូនល្អីនោះ។ គេយកវែកធំៗ ឬកូនផ្តិលមកដងយកទឹកក្បុងថ្លា មកចាក់ក្នុងកូនល្អីថ្មមៗ ចម្រោះយកទឹកក្បុងបញ្ចូលក្នុងពាងនោះ។

ខ. វិធីប្រមោក

១. ប្របាច់ត្រាំនឹងទឹកក្បុង

គេយកសូត្រមកគក់ប្របាច់ត្រាំនឹងទឹកក្បុង ចំនួនប្រហែលជា០២ម៉ោង ទើបគេស្រង់សូត្រពូតបញ្ចេញទឹក ទុកផ្អាប់សូត្រនោះ។

២. ដាំទឹកក្បុង

គេយកទឹកក្បុងដែលបោកគក់សូត្រនោះ ទៅដាំឲ្យពុះ ទើបគេយកសូត្រមកដាក់ស្ងោរជាមួយនឹងទឹកក្បុង។ ស្ងោរចំនួនប្រហែលជា២០នាទី គេស្រង់សូត្រមកស្ទាបមើល តើសរសៃសូត្រមានជាតិស្អិតទេ? បើមានជាតិស្អិត គេអាចយកសូត្រទៅលាងទឹកបានសូត្រមានសរសៃទន់។ គេស្រង់យកទៅលាងទឹក ហើយហាលឲ្យស្ងួត។ ការធ្វើបែបនេះគេហៅថាប្រមោកសូត្រ។

## VI. វិធីចងគាត

ការចងគាតនេះ គឺជាពិធីធ្វើហូលនីមួយៗឲ្យមានក្រលាគោម មានលក្ខណៈទៅជាក្បាច់ប្លែកៗ តាមចំណង់ចំណូលចិត្តរបស់មនុស្សអ្នកធ្វើហូលម្នាក់ៗ។ របៀបធ្វើហូលឲ្យមានលក្ខណៈប្លែកៗនោះ ដូចនេះ ៖

ក. វិធីអន្ទងសូត្រព័ទ្ធនឹងស្នឹងចង

គេយកសូត្រដែលបានប្រមោករួចហើយទៅរុំព័ទ្ធនឹងស្នឹងចង

១. ស្នឹងចង

ឈើពីរដុំ មានបណ្ដោយប្រហែលជា ០,១៥ម មានមុខកាត់ប្រហែលជា ០,១២ម X ០.០៨ម។ គេដាប់ដំនាប់សម្រាប់ស៊កមេបណ្ដោយ។ មេបណ្ដោយមានប្រវែងប្រហែលជា ១,២០ម ទៅ១,៣០ម មានមុខកាត់ប្រហែលជា ០,០៤ម X ០,៣០ម។ នៅពីលើឈើពីរដុំនោះ គេខួងដាក់ឈើមូលប៉ុនមេដៃ ប្រវែងប្រហែល ០,៣០ម ធ្វើជាស្នឹងសម្រាប់រុំព័ទ្ធសូត្រ។

២. ដាក់គាតដើមក្នុងស្នឹងចង

ពាក្យថា «គាតដើម» គឺគេយកអំបោះមកបែងជាកម្រង។ គេចងអំបោះដែលបានបែងជាកម្រងនោះ ទៅតាមក្បាច់គោមហូលដែលគេចង់បាន ទុកជាគម្រូសម្រាប់យកកម្រងសូត្រមកចងតាមគំរូនោះ។ គាតដើមនេះ, ស្រុកខ្លះហៅថា សូត្រដើមក៏មាន។

គេយកគាតដើម (គាតគំរូ) មកដាក់ក្នុងស្នឹងចង។ គេទាញស្នឹងឲ្យតឹងសរសៃគាតដើម។ គេចាប់វាយស្នៀតស្នឹងនោះឲ្យតឹងជាប់។ គេយកចន្ទល់មកទល់ចុងស្នឹងនោះឲ្យសរសៃគាតដើមតឹងស្មើ។

៣. អន្ទងសូត្រព័ទ្ធស្នឹងចង

គេយកសូត្រដែលក្រនៀវរួច ទៅខារដាក់ក្នុងបំពង់។ គេយកសូត្របំពង់ដែលខារបាននោះ មកបញ្ឈរក្បែរនោះ ។ គេយកសរសៃសូត្របំពង់នោះ មកប្រហកបញ្ចូលក្នុងដែកបង្កុងស្នូរអន្ទង។ គេចាប់យកសរសៃសូត្រនោះ មកទាញរុំព័ទ្ធស្នឹងចងនោះ។ គេរុំព័ទ្ធបានចំនួនពី ៨០ ទៅ១២០សរសៃ តាមសរសៃតូច ធំ។

កាលបើគេអន្ទងរុំព័ទ្ធស្នឹងចងបានគ្រប់ចំនួនសរសៃហើយ គេត្រូវចាប់ចងណា[1] នៅខាងចុងទាំងសងខាង ទើបគេចាប់ចងគោមហូលតាមគាតដើម។ [1]ចងណា គឺគេងចងរងជើង សម្រាប់ជាចំណាំចុងជាយហូល។

ខ. វិធីចងសូត្របែងជាក្រលាគោម

១. ចំណងគោម

ដោយយោលទៅលើការសាកសួរចាស់ៗ បានបញ្ជាក់ឲ្យឃើញថាមានការប្រើចំណង ០៣ បែប ដែលគេបានប្រើរួចមកហើយ។

A. ចំណងពីបុរាណ

ពីសម័យបុរាណ គេយកសូត្រមកវេញឲ្យខ្នាញ់ បានជាសរសៃធ្មារល្អិត។ គេយសរសៃសូត្រដែលបានវេញហើយនោះ មកធ្វើជាចំណងសម្រាប់ចងគាត ពីព្រោះពីសម័យបុរាណគេចងក្រលាគោមល្អិតណាស់។ បើយើងយកចំណងដែលមានសរសៃធំមកប្រើធ្វើជាចំណងគាតមិនអាចប្រើបានដូចបំណងទេ។

B. ចំណងសម័យកណ្ដាល

នៅសម័យដើម និងសម័យកណ្ដាលនៃសតវត្សទី២០នេះ គេយកដើមចេកជ្វាដែលគេដាំនៅកណ្ដាលថ្ងៃ មកបកយកស្រទបច្រៀកកូត ធ្វើជាចំណងសម្រាប់ចងគាត។

C. ចំណងសម័យសព្វថ្ងៃ

គេនៅតែយកចំណងដើមចេកជ្វា យកមកច្រៀកកូតធ្វើជាចំណងចងគាតដែរ តែនៅមានចំនួនតិច។ ឯចំនួនច្រើន គេយកសំបារទីឡុង (សំបារជ័រ) មកច្រៀកធ្វើជាចំណងសម្រាប់ចងគាតវិញ។

២. ចងតាមគាតដើម

កាលបើគេអន្ទងសូត្របានគ្រប់ចំនួនហើយ គេត្រូវខិតជុំគាតដើម និងសូត្រចង (សូត្រគាត) ឲ្យនៅជិតគ្នា។ គេយកចំណងចងសូត្រចុង តាមគំរូគាតដើម។ បើគេចងបាន០១ក្បាល (កម្រង) ហើយ គេដោះចន្ទល់ គេបញ្ចេញសូត្រចុង។ គេទល់ចន្ទល់វិញទើបគេអន្ទងសូត្រចុង និងចងគាតតាមបែបទី០១ដែរ។

សូមបញ្ជាក់ថា គេត្រូវចងសូត្រចុង (គាតចុង) យ៉ាងតិចណាស់ក៏ពីរក្បាល (កម្រង) ដែរ សម្រាប់យកទៅត្បាញហូលគោមក្នុក់ដើងម៉ា គោមធំក្បាលព្រហ្ម គោមក្អែក...។ មានចងសូត្រចុង (ស្រុកខ្លះហៅថាកូន) រហូតដល់០៩ក្បាលសម្រាប់ត្បាញហូលស្លឹកកញ្ចាប់...។

គេចាប់ទល់ចន្ទល់ និងអន្ទងរុំព័ទ្ធសូត្រចុង រហូតដល់បានគ្រប់ចំនួន ទើបគេខិតគាតដើម ជុំទី០២ឲ្យមកកៀកគ្នា ហើយគេចងគាតថ្មីនេះតាមគំរូគាតដើម ដូចមុនទៀត។ ការធ្វើបែបនេះ រហូតដល់អស់ជុំគំរូគាតដើម។

<u>គ. ដាក់គាតសនឹងស្នឹងសន្ទឹង</u>

គេយកគាតសមដាក់ក្នុងស្នឹងសន្ទឹង (ស្រុកខ្លះហៅថាស្នឹងផ្ដេក ស្នឹងផ្អែក)។ គេរៀបសរសៃគាតឲ្យស្មើល្អ ទើបគេទាញរឹតសរសៃគាតឲ្យតឹងស្មើ។ អ្នកស្ទាត់ជំនាញខាងគោម កាន់ខ្នៀសចូលទៅ

កេះ កៀសតម្រង់ចំណង់គោមឲ្យរត់ជួរតាមក្បាច់ដើម។ កាលបើគេកេះកៀស តម្រង់ចំណង់ក្បាច់បានល្អត្រឹមត្រូវហើយ ទើបគេដោះយកគាតនោះទៅដាក់ក្នុងស្នឹងរុំ។

លោក អ៊ិត វណ្ណានី កំពុងកានខ្មៀសកេះកៀសតម្រង់គោម។

<u>ឃ. ដាក់គាតនឹងស្នឹងរុំ</u>

១. ស្នឹងរុំ ស្រុកខ្លះហៅថា ស្នឹងផ្ទារ

ស្នឹងរុំនេះ គេធ្វើអំពីឈើពីរកំណាត់ដែលមានមុខកាត់ ០,០៧ម X ០,០៧ម ប្រវែងប្រហែលជា ០,០៤ម យកមកធ្វើជាមេទទឹង។ គេដាប់មេទទឹងទាំង ០២នេះ នៅចំកណ្ដាលសម្រាប់ស៊កមេបណ្ដោយ។ មេបណ្ដោយ មានមុខកាត់ ០,០៣ម x ០,៤០ម បណ្ដោយប្រវែងប្រហែលជា ១,២០ម ទៅ ១,៣០ម។ នៅចុងមេទទឹងទាំង០២ និងទាំងសងខាងគេដាប់ដំណាប់ដាក់បញ្ឈរ០៤។ នៅចុងខាងលើនៃមេបញ្ឈរទាំង០៤ គេខួងទម្លុះសម្រាប់ស៊កឈើមូល។ ឈើមូលនេះ គេសម្រាប់យកទៅស៊កក្បាលគាតទាំងសងខាង រឹតឲ្យតឹង សរសៃគាតវាយស្មៀតឲ្យជាប់។

២. មុខងារស្នឹងរុំ

កាលបើគេត្រូវការរុំគាតម្ដងៗក្ដីឬផ្ដាច់ចំណងគាតចេញក្ដី គេត្រូវយកស្នឹងនេះទៅដាប់គាតទាញសន្ធឹងឲ្យតឹងស្មើ ដើម្បីឲ្យស្រួលរុំឬស្រួលផ្ដាច់ចំណងចេញ។ នាង ហឿន ណារឿន កំពុងផ្ដាច់ចំណងគាត និងកំពុងរុំគាតបង្ហាញ។

## VII. វិធីជ្រលក់គាត

សូត្រដែលគេចងបានជាក្បាច់គោមហើយ គេហៅថា គាត។ ពីសម័យបុរាណគេជ្រលក់គាតត្បាញហូលដោយប្រើល័ក្ត០៣បែបគឺះ

១. ល័ក្តខ្មែរ
២. ល័ក្តព្រហូត
៣. ល័ក្តធ្ទះ

### ១. ល័ក្តខ្មែរ

ល័ក្តខ្មែរនេះ មានស្រុកខ្លះហៅថា ល័ក្តស្រម៉។ នៅក្នុងវចនានុក្រម សម្ដេចព្រះមហាសុមេធាធិបតីសង្ឃរាជគណៈមហានិកាយ ជ.ណ. ក៏ព្រះអង្គហៅថា ល័ក្តស្រម៉ដែរ។

<u>ក. វិធីបង្កើតជាដុំល័ក្ត</u>

ល័ក្ខខ្មែរនេះ កើតអំពីក្រុមមេសត្វល្អិតពួកមួយជាអ្នកបង្កបង្កើតឲ្យបានជាដុំ។

១. សណ្ឋានទ្រង់ទ្រាយ

ក្រុមសត្វល្អិតពួកនេះ មានសណ្ឋានតូចល្អិតដូចជាសត្វស្រមើល តែនៅត្រង់គូទវារាង់ប៉ោង ត្រលេងពេញដោយទឹក។ កាលបើយើងយកដៃទៅប៉ះ ឲ្យវាធូន់បន្តិចគូទវាបែក។ ទឹកនៅក្នុងគូទនោះ មានរសជាតិផ្អែមដូចជាទឹកឃ្មុំ។ បើវានៅជិតស្រមោចឬអង្ក្រង់ មេសត្វល្អិតពួកនេះមិនអាចរស់នៅជិតបានទេ ពីព្រោះសត្វសម្រោចឬអង្ក្រង់ស៊ីផាប់អស់។

២. ឈើដែលមេសត្វនៅបាន

មេសត្វល្អិតនេះ មិនអាចរស់នៅបានគ្រប់ដើមឈើទេលុះត្រាតែដើមឈើនោះមានក្រមរបែកក្រហេង់ក្រហូង ទើបមេសត្វល្អិតនេះចូលទៅជ្រករស់នៅបានដូចជា ទី០១ ដើម សង្កែ, ទី០២ ដើមកកោះ, ទី០៣ ដើមត្រាង់, ទី០៤ ដើមដោះតាព្រហ្ម, ទី០៥ ដើមចាមរី (អំពិលបារាំង), ...។

៣. ត្រូវពិនិត្យដើមឈើ

មុននឹងយកមេសត្វល្អិតនេះទៅលែងនៅដើមឈើណាមួយនោះ អ្នកចិញ្ចឹមត្រូវពិនិត្យដើមឈើនោះឲ្យបានច្បាស់លាស់ កុំឲ្យមានសត្វស្រមោចឬសត្វអង្ក្រង់ ឬក៏សត្វអ្វីមួយដែលមានលក្ខណៈប្រឆាំងនឹងមេល័ក្ខនោះ។

៤. វិធីចិញ្ចឹម

គេយកមេល័ក្ខ (មេសត្វល្អិត) ដែលនៅនឹងក្រមរឈើនោះដាក់ក្នុងកាតំ ឬក្រង់ចំបើងដាក់សម្បុកកូនល័ក្ខ នៅនឹងបាច់ចំបើង។ គេយកកាតំ ឬបាច់ចំបើងដែលដាក់មេល័ក្ខនោះ ទៅចង់ភ្ជាប់នឹងដើមឈើដែលបានពិនិត្យសព្វគ្រប់ហើយនោះ។

បើតាមជំនឿអ្នកចិញ្ចឹមល័ក្ខពីបុរាណ កាលបើគេចង់ឲ្យមេល័ក្ខបង្កើតបានជាកូនពូនជាចៅបង្កឲ្យបានជាដុំល័ក្ខ មានទឹកល្អ គេត្រូវដាំបាយដំនើប ពូតជា០៧ពំនូកយកដាក់ក្នុងបាច់ចំបើង ហើយយកទៅចង់ភ្ជាប់នឹងដើមឈើនៅជិតមេល័ក្ខនោះ។

៥. បេះយកដុំល័ក្ខ

លុះចិញ្ចឹមបានពី ០៥ ទៅ ០៦ខែ មេល័ក្ខបង្កជាកូន ពូនជាចៅ នៅគ្រប់មែក នៅគ្រប់ក្រលៀតក្រលោះ មានពណ៌សព្រាតពេញដើមឈើ មានទំហំប៉ុនមេដៃ ឬប៉ុនកូនដៃ។ គេបេះយកដុំមេល័ក្ខនោះទៅហាលថ្ងៃ ឲ្យមេល័ក្ខនោះងាប់ និងបានស្ងួតល្អ អាចយកទៅទុកដាក់បាន។

## ខ. វិធីធ្វើទឹកល័ក្ត

កាលបើគេបេះល័ក្តបានហើយ គេត្រូវរៀបចំធ្វើល័ក្តនោះឲ្យទៅជាទឹក សម្រាប់យកទៅជ្រលក់គាតបែបនេះ ៖

១. បុកលម្អិតល័ក្ត

គេត្រូវយកល័ក្តដុំធំៗ ដែលគេបានបេះពីដើមឈើមកនោះ ទៅដាក់ក្នុងត្បាល់ត្បៀងឬត្បាល់បុក, ជាន់ឬបុកល័ក្តឲ្យល្អិតល្មមៗ គេយកកញ្ច្រែងអង្ករមករែងៗ បើនៅធំៗគេយកទៅចាក់ដាក់ក្នុងត្បាល់ត្បៀងឬត្បាល់បុក, ជាន់ឬបុកឲ្យល្អិតល្មមហើយបារយកទៅរែងរហូតដល់បានសម្រេចៗ

ការបុក, ជាន់ និងបារយកទៅរែងនេះ បើល័ក្តនៅដុំធំពេកក៏មិនល្អ បើល្អិតពេកក៏មិនល្អៗ បើនៅដុំប៉ុនគ្រាប់អង្ករ ទើបមានលក្ខណៈល្អណាស់ៗ

សូមបញ្ជាក់ថា ពេលបុកល័ក្ត បើល័ក្តស្ងួតពេក វាអាចហុយឡើង គេយកទឹកទៅប្រោះឲ្យសើម កុំឲ្យល័ក្តហុយចេញច្រើន និងកុំឲ្យល័ក្តកំពុបច្រើន ពីព្រោះជាតិល័ក្តស្រួយពេកៗ

២. ចាក់ទឹកត្រាំល័ក្ត

កាលបើបុកល័ក្ត និងរែងល័ក្តបានល្អហើយ គេត្រូវយកល័ក្តដែលបានសម្រេចហើយនោះទៅចាក់ដាក់ក្នុងពាងដី ឬខាប់ដីធ្វើអំពីដីដុត (ហាមប្រើពាងស៊ីម៉ង់)ៗ គេយកទឹកភ្លៀង ឬទឹកទន្លេដែលគេកូរសាច់ជូរថ្លាល្អ ទៅចាក់ក្នុងពាងដី ឬខាប់ដីដែលដាក់ល័ក្តនោះឲ្យល្មម គឺឲ្យល័ក្តនៅខាប់ល្អ មិនឲ្យរាវពេកទេៗ លុះត្រាំល័ក្តបានមួយយប់ គេយកពាងដី០៣សម្រាប់ត្រងយកទឹកល័ក្តៗ

ពាងទី០១ កាលបើគេត្រាំល័ក្តបានគ្រប់ចំនួនពេលហើយគេត្រូវយកល័ក្តដែលត្រាំនោះមកបារដាក់ក្នុងល្អីនៅលើមាត់ពាងដីទី០១ ដែលគេបានរុំព័ទ្ធទ្រាប់ដោយស្លឹកចេកជុំវិញដើម្បីឲ្យទឹកល័ក្តហូរចូលចំពាងដីៗ គេចាក់ទឹកត្រាំល័ក្តនោះឲ្យហូរយឺតៗៗ ទឹកល័ក្តដែលនៅសល់គេយកមកចាក់បង្ហូរតិចៗបញ្ចូលក្នុងពាងដីទី០១ នេះដែរៗ គេទុកល័ក្តក្នុងល្អីលើមាត់ពាងដីទី០១នេះឲ្យហូរស្រស់ទឹក ទើបគេលើកល្អីល័ក្តដែលនៅលើមាត់ពាងដីទី០១នេះ ទៅដាក់លើមាត់ពាងទី០២ទៀតៗ ទឹកល័ក្តដែលគេចម្រោះបញ្ចូលក្នុងពាងទី០១ នេះហៅថា ទឹកទី០១, ទឹកល័ក្តទី០១ឬទឹកដើមៗ

ពាងដីទី០២ គេយកទឹកមកចាក់ចម្រោះឲ្យហូរច្រោះចូលពាងដីទី០២នេះទាល់តែជិតអស់ជាតិល័ក្តៗ ទឹកចម្រោះល័ក្ត ដែលបានច្រោះចូលក្នុងពាងដីទី០២នេះ គេហៅថាទឹកទី០២ ទឹកល័ក្តទី០២ឬទឹកកណ្ដាលៗ

ពាងទី០៣ គេលើកយកល្អីល័ក្តដែលដាក់លើមាត់ពាងដីទី០២នេះ ទៅដាក់លើមាត់ពាងដីទី០៣ទៀត ហើយគេចាក់ទឹកចម្រោះរហូតដល់ទឹកស្រក់ថ្លា ទើបគេបញ្ឈប់ចាក់ទឹកបន្តទៅទៀត។ ការចាក់ទឹកចម្រោះលើកនេះ មិនមានកំណត់ចំនួនទឹកឡើយ។ ទឹកចម្រោះដែលធ្លាក់ចូលក្នុងពាងប្រភេទទី០៣នេះ គេហៅថា ទឹកទី០៣ឬទឹកចុង។

ដុំល័ក្តដែលនៅសល់ពីគេចម្រោះនោះ គេយកទៅស្ងួតចាក់ដាក់លើស្រទបចេក សម្រាប់លក់ឲ្យអ្នកបិទនង្គ័លឬសម្រាប់យកផ្សារអ្វីផ្សេងៗ។

គ. វិធីធ្វើទឹកម្ជូរ

ទឹកម្ជូរក្នុងវិធីធ្វើហូលនេះ មាន០២យ៉ាងគឺ:

១. ទឹកម្ជូរព្រៃ គឺទឹកម្ជូរដែលបានមកពីការស្ងោរស្លឹកអំពិល ស្លឹកសណ្តាន់ ឬផ្លែសណ្តាន់...។

២. ទឹកម្ជូរស្រុក គឺទឹកម្ជូរដែលបានមកអំពីការស្ងោរដុំសាច់ដូរ។ ទឹកម្ជូរទាំង០២ប្រភេទនេះ គឺគេស្ងោរទុកឲ្យបានហើយស្រេច សម្រាប់ដល់ពេលត្រូវការគេយកទៅប្រើប្រាស់ភ្លាមៗ។

ឃ. វិធីស្ងោរយកទឹកល័ក្ត

កាលបើគេច្រោះទឹកល័ក្តដើម (ទឹកទី០១) បានហើយ គេយកទឹកល័ក្តដើមនេះទៅស្ងោរ ។ លុះទឹកនោះពុះឡើង គេយកទឹកម្ជូរព្រៃចំនួន០១វែក ឬ០២វែកទៅចាក់ដាក់ទឹកល័ក្តកំពុងពុះ ហើយកកូរឲ្យឡើងពពុះកករច្រើន ទើបគេដួសពពុះកករនោះចោល។ គេយកទឹកល័ក្តដែលស្ងោរនោះ ទៅចាក់ច្រោះលើសំពត់ផាឱប បញ្ចូលទឹកល័ក្តទុកក្នុងពាងដីនោះដដែល។

បន្ទាប់មក កាលបើគេចម្រោះទឹកកណ្តាលបានហើយ គេយកទឹកកណ្តាល (ទឹកទី០២) នេះទៅស្ងោរឲ្យពុះ ហើយយកទឹកម្ជូរព្រៃដាក់បញ្ចូលក្នុងទឹកល័ក្តកំពុងពុះនោះ ដូចកាលគេស្ងោរទឹកល័ក្តដើមដែរ។ គេចាក់ច្រោះទឹកល័ក្តកណ្តាល ដូចទឹកដើមទៀត ទុកក្នុងពាងដីទី០២ដដែល។

បន្ទាប់មកទៀត គេយកទឹកចុង (ទឹកទី០៣) ទៅស្ងោរ នឹងធ្វើដូចទឹកដើម ទឹកកណ្តាលដែរ។ តែទឹកចុងនេះ គេច្រោះឲ្យបានច្រើនពាង ដាំឲ្យបានច្រើនឆ្នាំង ទុកសម្រាប់សេចក្តីត្រូវការ។

គេត្រូវទុកទឹកដើម ទឹកកណ្តាល ទឹកចុង ឲ្យនៅក្នុងពាងដាច់ដោយឡែកៗពីគ្នាគេមិនត្រូវដាក់បញ្ចូលគ្នាទេ។

ង. ស្ងោរជាមួយទឹកម្ជូរស្រុក

កាលបើគេចងគាតបានហើយ គេចាប់ថ្លឹងគាត និងថ្លឹងសាច់ដូរ។ គេថ្លឹងសាច់ដូរឲ្យមានទម្ងន់០១ភាគ០២នៃទម្ងន់គាត។

*មុននឹងស្ងោរគាតជាមួយទឹកសាច់ជូរ គេត្រូវរៀបចំ ៖*

*១. គេយកគាតទៅត្រាំជាមួយនឹងទឹកភ្លៀង គេច្របាច់ឲ្យទឹកជ្រាបចូលសព្វសរសៃសូត្រ។*

*២. បើតាមជំនឿ ពេលស្ងោរសូត្រម្ដងៗ គេត្រូវអុជធូប០១សរសៃ និងម្ជូ០១ម៉ាត់យកទៅដាក់នៅក្បែរចង្ក្រានស្ងោរសូត្រនោះ។*

*៣. គេស្ងោរទឹកសាច់ជូរ ០១ភាគ០២ នោះឲ្យពុះ ទើបគេច្របាច់គាតពូតបោកឲ្យសសោះសរសៃសូត្រ ដាក់ស្ងោរជាមួយនឹងទឹកសាច់ជូរ។*

*កាលបើស្ងោរពុះល្អហើយ គេស្រង់យកគាតមកជ្រុំ ច្របាច់ ញី ក្នុងពេលទឹកនៅក្ដៅល្មម ដើម្បីធ្វើឲ្យសរសៃគាតជ្រាបទឹកចូលសព្វសាច់។ បើទឹកនោះត្រជាក់គេចាក់ទឹកនោះទៅក្នុងឆ្នាំងវិញ។ គេដងយកទឹកក្ដៅថ្មី ពីក្នុងឆ្នាំងស្ងោរគាតមកចាក់ពីលើគាតចាប់ជ្រុំ បោកច្របាច់ ញី ម្ដងទៀត ដើម្បីធ្វើឲ្យទឹកសាច់ជូរជ្រាបចូលសព្វសាច់ដាច់ត្រឹមចំណង។*

*លុះគេបោក ច្របាច់ ញី បានពីរ ឬបីដងហើយ គេចាប់ស្រាយចំណងគាតត្រង់កន្លែងដែលមានចំណងញឹក ដើម្បីពិនិត្យមើល។ បើគេពិនិត្យឃើញថា មិនទាន់ចូលល្អទេ គេចងចំណងគាតវិញ។ គេដួសយកទឹកស្ងោរនោះមកចាក់ពីលើគាត ចាប់ជ្រុំ ច្របាច់ ញីរហូតចូលដាច់ត្រឹមចំណង។*

*បើនៅតែមិនទាន់ដាច់ គេចាប់ពូតគាត ហើយចាក់ទឹកសាច់ជូរបន្ថែមទៅក្នុងឆ្នាំងគេដងទឹកក្តៅពីក្នុងឆ្នាំងមកចាក់ពីលើគាត បោក ច្របាច់ ញី រហូតទាល់តែចូលដាច់ល្អ។ បើចូលដាច់ល្អហើយ គេត្រូវយកគាតនោះទៅស្ងោរ០១អំពុះម្ដងទៀត ទើបគេចាក់ទឹកសាច់ជូរទុកសម្រាប់ប្រើការបន្តទៅទៀត។*

*<u>ច. វិធីជ្រលក់គាត</u>*

*គេយកទឹកចុង (ទឹកទី០៣) ទៅដាំឲ្យពុះ។ គេយកគាតទៅដាក់ស្ងោរ ក្នុងទឹកចុងកំពុងពុះនោះ។ គេស្រង់យកមកបោក ជ្រុំ ច្របាច់ ញី ឲ្យបាន០២ ឬ០៣ដង។ គេស្រាយចំណងគាតត្រង់កន្លែងដែលមានចំណងញឹក ពិនិយត្យមើលថាតើទឹកល័ក្តចូលដាច់ទេ? បើមិនទាន់ដាច់ទេ គេចងចំណងគាតវិញ។ គេចាប់ស្ងោរនឹងស្រង់យកមកបោកជ្រុំ ច្របាច់ ញីឲ្យទាល់តែចូលដាច់។ បើចូលដាច់ហើយ គេពូតគាតសំដិលឲ្យស្រស់ទឹក។*

*ទឹកចុងដែលស្ងោរជាមួយគាតនោះ គេចាក់ទុកមួយកន្លែង សម្រាប់ទុកធ្វើជាទឹកទល់[1] ។*

*[1] ទឹកទល់នេះ គឺទឹកសាច់ជូរ និងទឹកល័ក្តទី០៣លាយគ្នា ជាទឹកដែលគេទុកបម្រុងសម្រាប់ដល់ពេលជ្រលក់គាតមិនចូលសោះ គេយកទឹកទល់នេះមកចាក់ចូលបន្តិច ទើបគេជ្រលក់គាតចូលវិញ។*

បន្ទាប់ពីការពិនិត្យឃើញថា ល័ក្តចូលដាច់ហើយ គេយកទឹកល័ក្តដើម (ទឹកទី០១) គឺទឹកល័ក្តខាប់ ដែលយើងបានចម្រោះយកមុនគេទៅស្ងោរឲ្យពុះ។ គេយកគាតមកស្ងោរជាមួយនឹងទឹកល័ក្តដើមនោះ ទើបគេស្រង់យកមកបោកជ្រុំប្របាច់ញី ឲ្យល័ក្តជ្រាបចូលដាច់ចំនួន០៣ឬ០៤ដង។

កាលបើល័ក្តចូលដាច់ហើយ ទើបគេចាក់ទឹកល័ក្តលាយគ្នា ឧទាហរណ៍ទឹកល័ក្តដើម០១វែក ទឹកល័ក្តកណ្តាល០២វែក ទឹកចុង០៣វែក តាមការកំណត់សម្គាល់ថាបើគាតជិតពណ៌តិចគេត្រូវដាក់ទឹកល័ក្តដើមច្រើន។ តែបើគាតជិតពណ៌ខ្លាំងវិញ គេត្រូវបន្ថយទឹកល័ក្តដើមឲ្យនៅតិច ឬគេមិនដាក់ទឹកល័ក្តដើម គេដាក់តែទឹកល័ក្តកណ្តាល ឬទឹកល័ក្តចុងឲ្យច្រើន។

គេស្ងោរ០១អំពុះ ទើបគេស្រង់យកមកបោក ជ្រុំ ប្របាច់ ញី ឲ្យបានច្រើនដងគេស្រាយចំណងគាតត្រង់កន្ទែងញី ពិនិត្យម្តងទៀត។ បើពិនិត្យឃើញថា គាតវាមិនលេបគេយកវាទៅលាងទឹក។ រួចគេយកមកស្ងោរនឹងទឹកទល់ ហើយគេយកទឹកល័ក្តដើម ទឹកល័ក្តកណ្តាល ទឹកល័ក្តចុង មកចាក់បញ្ចូលជាមួយគ្នាស្ងោរ ០២ឬ០៣ដងទៀត។

បើវារលឹម (ពាក្យអ្នកត្បាញថាវាចូលជ្រុលហួសចំណង) គេបង់សាច់ដូរ០១ដុំប៉ុនមេដៃដើម្បីខណ្ឌល័ក្តកុំឲ្យវាចូលជ្រុល។ បើយើងបង់សាច់ដូរ០១ដុំខណ្ឌវាលែងជ្រៀតចូលទៀតហើយ។ តែបើគេសង្កេតពិនិត្យឃើញថា ល័ក្តចូលបែបណាគេត្រូវចាក់ទឹកល័ក្តដើមប៉ុន្មាន ទឹកល័ក្ត កណ្តាលប៉ុន្មាន ទឹកល័ក្តចុងប៉ុន្មាន តាការសង្កេតរបស់អ្នកជ្រលក់គាត។ តែបើគេយល់ថា ទឹកល័ក្តចូលល្អហើយ គេត្រូវយកទឹកល័ក្តចុង (ទឹកទី០៣) ទៅស្ងោរឲ្យបានច្រើនដងដើម្បីឲ្យសូត្រឆ្អែតល័ក្តល្អ ហើយមានពណ៌រលោង។ រាល់ការស្ងោរគាតគ្រប់ទឹក គេតែងច្រូចទឹកម្ជូរព្រៃបន្តិច និងទឹកទល់បន្តិច។ បើគាតមានពណ៌ស្រអាប់ គេច្រូចទឹកម្ជូរព្រៃឲ្យច្រើនជាងទឹកទល់។ តែបើគាតមានពណ៌ស្រស់ពេកវិញ គេត្រូវច្រូចទឹកទល់ឲ្យច្រើនជាងទឹកម្ជូរព្រៃ។ កាលបើគេជ្រលក់គាតបានសម្រេចហើយ គេត្រូវយកគាតទៅលាងនឹងទឹកភ្លៀងឬទឹកទន្លេ ដែលគេកូរសាច់ដូរឲ្យទឹកថ្លា។ ការបោកសាង បែបនេះគេត្រូវធ្វើ០៨ឬ០៩ដង រហូតដល់ល័ក្តលែងចេញពណ៌ ទើបគេយកគាតទៅសំដិលហាលឲ្យស្ងួតល្អ។

### ២. ល័ក្តព្រហូត

ព្រហូតជាដើមរុក្ខជាតិមួយប្រភេទមានស្លឹកធំក្រាស់ ស្រដៀងនឹងមង្ឃុតស្ទើរចាប់ច្រឡំ។ ឈើនេះមានសម្បកក្រាស់ផ្លែមូលមានរសជាតិជូរ។ គេដាំដើមព្រហូត សម្រាប់ស្ងោះសម្បកធ្វើល័ក្តព្រហូត។

ក. វិធីធ្វើឲ្យទៅជាល័ក្តព្រហូត

ល័ក្តព្រហូតនេះ គេធ្វើអំពីសម្បកដើមព្រហូត តែបើគ្មានសម្បកដើមព្រហូតទេ គេអាចយកខ្ទឹមដើមព្រហូត មកចាំងយកកម្ទេចស្ងោរធ្វើជាល័ក្តព្រហូតក៏បាន។ វិធីធ្វើបែបនេះ ៖

១. កាប់ចិញ្ច្រាំ ឬចាំង

ទោះគេស្ទោះយកសម្បកមកចិញ្ច្រាំក្តី ទោះគេយកខ្ទឹមមកចាំងយកចំណាំងក្តី គេត្រូវកាប់ចិញ្ច្រាំឲ្យល្អិត ឬចាំងយកចំណាំងល្អិតទៅដាក់ស្ងោរ ដើម្បីឲ្យជាតិព្រហូតឆាប់ចេញពណ៌អស់ពីសម្បក ឬខ្ទឹម។ បើគេកាប់ចិញ្ច្រាំ ឬចាំងបានល្អិតល្អ ការស្ងោរក៏មានភាពងាយស្រួលដែរ។

២. វិធីស្ងោរ

គេយកសម្បកព្រហូតដែលគេចិញ្ច្រាំបានល្អហើយក្តី គេយកចំណាំងដែលគេចាំងបានល្អហើយក្តី គេយកទៅដាក់ក្នុងឆ្នាំងចាក់ទឹកដុតភ្លើងរំងាស់ឲ្យបានយូរ ឲ្យជាតិព្រហូតចេញពណ៌លឿងស្រអាប់រងថ្វាបានល្អ។ កាលបើពិនិត្យឃើញថា ជាតិព្រហូតចេញពីសម្បក ឬខ្ទឹមហើយ គេត្រូវរៀបចំច្រោះឲ្យបានស្អាត កុំឲ្យមានកម្ទេចល្អិតនៅជាមួយនឹងទឹក។

៣. វិធីចម្រោះ

គេយកសំពត់ថាឱបមកដាក់ក្រាល ក្នុងកូនល្អីជាដើម។ គេយកកូនល្អីនោះ ទៅដាក់លើមាត់ពាងដី។ ទើបគេដងទឹកស្ងោរសម្បកព្រហូតនោះ មកចាក់លើសំពត់ផាឱបចម្រោះទឹកព្រហូតបញ្ចូលក្នុងពាងដី។

៤. បង់សាច់ជូរ

កាលបើគេចម្រោះទឹកព្រហូតដាក់ក្នុងពាងបានហើយ គេដាក់ដុំសាច់ជូរក្នុងទឹកព្រហូតចាប់កកូរឲ្យសាច់ជូររលាយអស់ ទឹកព្រហូតឡើងពណ៌លឿងស្រអាប់រងថ្វា។ បើពណ៌ព្រហូតមិនទាន់លឿងស្រអាប់រងថ្វាទេ គេបន្ថែមសាច់ជូររួចកូរឲ្យរលាយ ទាល់តែទឹកព្រហូតឡើងពណ៌លឿងស្រអាប់រងថ្វាល្អ។

៥. ចងនិងផ្តាច់ចំណងគាតម្តងទៀត

គេយកគាតទៅហាលឲ្យស្ងួត ទើបគេយកចំណងគាត មកចងសង្កត់ត្រង់កន្ទែងដែលយើងត្រូវជ្រលក់ល័ក្តខ្មៅរហើយ។ គេចាប់ផ្តាច់ចំណងគាត ដែលយើងត្រូវជ្រលក់ល័ក្តព្រហូត។

សូមពិនិត្យមើលរូបដែលកំពុងផ្តាច់ចំណងគាត និងចងគាតវិញ នៅត្រង់លេខ០១មុខងារស្នឹងរុំ។

## ខ. វិធីធ្វើជ្រលក់ព្រហូត

### ១. ស្ងោរគាតជាមួយទឹកព្រហូត

កាលបើគេចងគាត និងផ្ដាច់ចំណងគាតរួចស្រេចបាច់ហើយ គេដាំទឹកព្រហូតឲ្យពុះទើបគេយកគាតទៅស្ងោរជាមួយនឹងទឹកព្រហូតនោះ។ ការស្ងោរជាមួយនេះ មិនឲ្យស្ងោរយូរពេកទេ ខ្លាចល័ក្តរលឹម(1) បើស្ងោរយូរណាស់០២អំពុះ។ គេស្រង់យកគាត មកបោកប្រហ្សាច់ញី ឲ្យទឹកល័ក្តជ្រាបចូលសព្វសរសៃគាត។ (1) ល័ក្តខ្មៅរជ្រៀតចូលទៅក្នុងចំណងគាត

### ២. បោកជ្រុំ ប្រហ្សាច់ ញី

គេស្រង់យកគាតមក បោកជ្រុំ ប្រហ្សាច់ ញី ឲ្យបានច្រើនដង បើទឹកត្រជាក់គេចាក់ទឹកនោះទៅក្នុងឆ្នាំងទឹកល័ក្តវិញ ទើបគេដងយកទឹកនៅក្ដៅ មកបោកជ្រុំ ប្រហ្សាច់ ញីទៀត។

### ៣. យកគាតមកលាងនឹងទឹកភ្លៀង

កាលបើគេស្ងោរនិងប្រហ្សាច់ ញី បានចំនួន ០២ទឹក ឬ០៣ទឹកហើយ គេយកគាតទៅបោកជាមួយនឹងទឹកភ្លៀងឲ្យជ្រះ ទើបគេយកទៅសំដិលឲ្យស្រពោន បានគេយកមកដាក់ស្ងោរជាមួយនឹងទឹកព្រហូតបន្តទៅទៀត។

នាងកើត សេន បោកលាងរួចយកទៅពាក់ព្យួរឲ្យស្រស់ទឹក។

### ៤. ស្ងោរឲ្យបានច្រើនដង

ការស្ងោរគាតជាមួយនឹងទឹកព្រហូតនេះ ហើយស្រង់យកមកបោកជ្រុំ ប្រហ្សាច់ ញី ឲ្យបានចំនួន០២ទឹក ឬ០៣ទឹក ទើបគេយកគាតទៅបោកលាងជាមួយនឹងទឹកភ្លៀងម្ដង។ ការធ្វើបែបនេះឲ្យបានច្រើនដង រឹតតែល្អ។ ការស្ងោរគាតជាមួយនឹងល័ក្តព្រហូត ការបោកជ្រុំ ប្រហ្សាច់គាត ការលាងគាតនឹងទឹកភ្លៀង ឲ្យបានច្រើនដង យ៉ាងតិចជាង១០ដង ទើបល័ក្តព្រហូតមិនចេញពណ៌ មិនហើរពណ៌ នៅជាប់ពណ៌ល្អកាលនោះ។ កាលបើគេយល់ថាល្មមហើយ គេយកគាតទៅសំដិលហាលឲ្យស្ងួត។

## គ. វិធីបន្ទំគាត

គេយកគាតទៅបន្ទំនឹងទឹកក្បុង ដើម្បីឲ្យគាតមានពណ៌រលោងល្អ ៖

### ១. ដាំទឹកក្បុង

គេយកទឹកក្បុង ដែលបានចម្រោះឲ្យស្អាត ទុកក្នុងពាងដីពីពេលមុននោះ មកដាំឲ្យពុះ។ កាលបើទឹកក្បុងកំពុងពុះ គេត្រូវយកគាត០១ខ្នារទៅជ្រលក់ពិសោធ។

២. ពិសោធន៍

គេយកសូត្រ ដែលយើងរុំព័ទ្ធស្អិតពីចំនួន ៨០ ទៅ១២០ សរសៃ តាមសរសៃតូច ធំ ចងមួយដុំនោះ មកជ្រលក់នឹងទឹកក្បុងកំពុងពុះនោះ ដើម្បីពិសោធន៍ឲ្យដឹងថា ទឹកក្បុងនេះវាសាប ឬវាប្រៃ ឬវាល្មម។ បើវាប្រៃខ្លាំង ធ្វើឲ្យល័ក្តខ្មែរ គឺល័ក្តក្រហមរេចេញ។ បើវាសាប ធ្វើឲ្យគាតមានពណ៌មិនល្អឿងទុំល្អ បើវាល្មមធ្វើឲ្យគាតមានពណ៌លឿងរលោងល្អ។

៣. បន្ទុំគាត

បើគេពិសោធន៍នឹងទឹកក្បុងបានដឹងថា ល្មមល្អហើយ គឺមិនប្រៃពេក ហើយមិនសាបពេក។ គេយកគាតទាំងអស់ ទៅស្ងោរជាមួយនឹងទឹកក្បុងកំពុងពុះ ចំនួនមួយអំពុះ ទើបគេស្រង់មកលាងទឹកឲ្យជ្រះ គេយកគាតទៅសំដិលហាលឲ្យស្ងួតល្អ។ ការធ្វើបែបនេះដើម្បីបន្ទុំគាតឲ្យ មានពណ៌លឿងរលោងល្អ។ ពេលលាងម្តងៗក្តី ពេលបន្ទុំ ហើយលាងក្តីគេតែងយកមកពាក់ សំដិលឲ្យស្រស់ទឹក ឬឲ្យស្ងួតល្អបែបនេះ។

**៣. ល័ក្តធ្វះ**

ល័ក្តធ្វះ កើតអំពីមរ។ មរកើតអំពីដើមត្រុំ។ ដើមត្រុំមាន០៣បែបគឺ ដើមត្រុំព្រៃ, ដើមត្រុំមួរ, ដើមត្រុំស្រុក។ ដើមត្រុំដែលគេយកមកធ្វើជាមរ គឺដើមត្រុំស្រុក។

<u>ក. វិធីធ្វើឲ្យជាមរ</u>

១. សណ្ឋានទ្រង់ទ្រាយដើមត្រុំ

ដើមត្រុំជាដំណាំដើមតូច មានស្លឹកល្អិត ផ្លែចង្កោមច្រើន ផ្លែមួយៗ រាងខុបចុងដើម។ ដើមត្រុំមានស្លឹកស្រដៀងនឹងស្លឹកម្រុំ ឯដើមស្រដៀងនឹងដើមសណ្តែកខ្មោច។

២. វិធីដាំដំណាំត្រុំ

ដំណាំត្រុំនេះ គេច្រើនដាំនៅចុងខែចេត្រ។ មុននឹងដាំគេត្រូវកាប់ជ្រុំដី ឬភ្ជួររាស់ឲ្យល្អិត ល្អទើបគេយកគ្រាប់មករោយ ឬព្រោះលើដីដែលខ្លួនបានធ្វើហើយ។ ដំណាំនេះគេច្រើនដាំតាម មាត់ស្ទឹង ឬមាត់ទន្លេ។

៣. ប្រមូលដំណាំត្រុំ

កាលបើគេដាំដើមត្រុំបានចំនួន០៣ខែកន្លះ គេត្រូវពិនិត្យដំណាំត្រុំ តើមានផ្លែចាស់ហើយឬនៅ? បើពិនិត្យឃើញថា ផ្លែចាស់ខ្លះ ស្រគាសខ្លះ ទុំខ្លះហើយ គេត្រូវប្រមូលដើមត្រុំយកមកសំដិលថ្ងៃទុកឲ្យស្រពោន។

៤. ត្រាំដើមត្រុំ

បើគេពិនិត្យឃើញថា ដើមត្រុំមានសភាពស្រពាប់ដោយកម្ដៅថ្ងៃ ហើយគេត្រូវកង់យកទៅប្រមូលញាត់ក្នុងពាង ឬធុងឈើធំៗ។ គេដង់ទឹកចាក់ដាក់ក្នុងពាង ឬក្នុងធុងឈើដែលគេដាក់ដើមត្រុំនោះ។

ក្រោយពេលត្រាំ អស់រយៈពេលចំនួន២១ម៉ោង ឬ២៣ម៉ោង គេត្រូវទៅពិនិត្យពពុះចេញពណ៌ខៀវបែបស្វាយហើយឬនៅ? បើមិនទាន់បែកពពុះចេញពណ៌ខៀវបែកស្វាយទេ គេត្រូវរង់ចាំអស់រយៈពេល០៣ ឬ០៤ម៉ោងទៀត រហូតដល់ពពុះចេញពណ៌ខៀវបែកស្វាយ។ បើគេពិនិត្យឃើញពពុះចេញពណ៌ខៀវបែកស្វាយហើយ គេត្រូវស្រង់ដើមនឹងស្លឹកត្រុំនោះចេញ។ បើគេពិនិត្យឃើញមានស្លឹកជ្រុះនៅក្នុងពាង ឬធុងឈើ គេយកកញ្ច្រែងមកលូកដង់យកស្លឹកចេញឲ្យទាល់តែអស់។

៥. ដាក់កំបោរលៀស

គេយកកំបោរលៀសទៅដាក់ក្នុងពាង ឬធុងឈើ ដែលត្រាំដើមត្រុំនោះ ចំនួន ០៣គីឡូក្រាម ប្រសិនបើទឹកត្រាំ០១ពាងព្រែនគរ។ បើដាក់កំបោរច្រើនពេក វាមានជាតិប្រៃជ្រុល បណ្ដាលឲ្យមានគុណភាពមិនល្អ តែបើវានៅសាប គេអាចដាក់កំបោរបន្ថែមទៀតបាន។ កាលបើគេដាក់កំបោរហើយ គេយកឈើច្រវា មកឈរកកូរឲ្យអស់រយៈពេលពី០១ម៉ោងទៅ ០២ម៉ោងរហូតដល់ទឹកឡើងល្អក់។ បើឈប់កូរ ទឹកវិលមានខ្សែទឹករង់ថ្លាទើបបាន។ បើមិនទាន់មានខ្សែទឹករង់ថ្លាទេ គេត្រូវដាក់កំបោរបន្ថែមទៀត ពីព្រោះវានៅសាប។ គេចាប់កកូរម្ដងទៀតរហូតដល់គេពិនិត្យឃើញខ្សែរទឹកវិលរង់ថ្លា ទើបគេឈប់កូរបន្តទៅទៀត។

៦. ជីកដីធ្វើរណ្ដៅ

កាលបើគេឈប់កូរ គេត្រូវទុក០១យប់ ទើបគេទៅចាក់សម្រិតទឹកថ្លាចោល ទុកតែទឹកខាប់អន្ទឹលៗ។ គេជីកដីធ្វើរណ្ដៅ គេយកសំពត់ផាឌឹកទៅក្រាលក្នុងរណ្ដៅនោះ។ គេចម្រោះទឹកឲ្យជ្រាបចូលទៅក្នុងដី ទុកឲ្យនៅតែទឹកខាប់អន្ទឹលៗ។ ទឹកខាប់អន្ទឹលៗនេះគេហៅថា «មរ»។

<u>ខ. វិធីធ្វើមរឲ្យជាធ្វះ</u>

១. វិធីធ្វើទឹកក្បុង

គេដុតដើមផ្ទីធ្វើក្បុង ចាក់ទឹកលាយក្បុង និងចម្រោះទឹកក្បុងបញ្ចូលក្នុងពាងដីទុកឲ្យបានច្រើនពាងដី។

២. វិធីលាយមរ

គេចាក់ទឹកក្បុងកន្ទះពាង គេយកមរបន្តិច កំបោរបន្តិច និងស្ករក្រហមបន្តិចទៅដាក់លាយក្នុងពាងទឹកក្បុងនោះ។ រួចគេយកកំណាត់ឈើកូររឹកមួយសន្ទុះ គេឈប់កូរហើយទុកវាចោល។ រាល់ថ្ងៃជាបន្តបន្ទាប់ គេតែងទៅយកមរបន្តិច កំបោរបន្តិច ស្ករក្រហមបន្តិច និងទឹកក្បុង០១ត្រលោក ទៅដាក់ក្នុងពាងទឹកក្បុងដែលនោះ រួចគេយកកំណាត់ឈើកូររឹក ឲ្យបានយូរបន្តិច ដើម្បីឲ្យជាតិមរ កំបោរ ស្ករក្រហម និងទឹកក្បុងរលាយចូលគ្នា។

ការធ្វើបែបនេះ ជារៀងរាល់ថ្ងៃ អស់រយៈពេលយ៉ាងឆាប់ណាស់ក៏កន្ទះខែដែរ។ ការរង់ចាំមើលរហូតដល់ជាតិមរ កំបោរ ស្ករក្រហម និងទឹកក្បុងរលាយចូលគ្នា បែកពពុះខៀវក្រមៅទើបល្អ។ បើធ្វះនៅបែកពពុះស មិនទាន់ល្អទេ។

គេត្រូវបន្ថែម ឬបន្ថយជាតិទាំងអស់នោះ រហូតដល់ពពុះឡើងពណ៌ខៀវក្រមៅទើបគេសន្មតថាជាតិធ្វះ មានពណ៌ល្អហើយ។

<u>គ. វិធីជ្រលក់ធ្វះ</u>

១. ចងគាត និងផ្ដាច់ចំណងគាត

គេត្រូវចងគាត ត្រង់កន្ទៃងជ្រលក់ព្រហូតឲ្យជិតវិញ ទើបគេផ្ដាច់ចំណងគាតត្រង់កន្ទៃងដែលត្រូវជ្រលក់ធ្វះ ឲ្យជាតិធ្វះចូលជិតជាប់សរសៃសូត្រ។

២. យកគាតត្រាំទឹក

គេយកផ្លៃសណ្ដាន់មកត្រាំឲ្យចេញជាតិជូរ។ គេយកស្ករក្រហម (ស្ករពាង) មកលាយនឹងទឹកម្ជូរផ្លៃសណ្ដាន់ត្រាំនោះ កកូរឲ្យរលាយសព្វ។ គេយកគាតមកត្រាំនឹងម្ជូរនោះ រួចប្រូបាច់ ញីឲ្យចូលជ្រាបសព្វសាច់។

៣. ជ្រលក់គាត

បើគេយកគាតទៅប្រូបាច់ធ្វះ ក្នុងពាងទី០១, រួចគេយកទៅប្រូបាច់ក្នុងពាងទី០២ទៀត, បន្ទាប់មកគេយកទៅប្រូបាច់ធ្វះ ក្នុងពាងទី០៣ទៀត, ទើបគេយកគាតទៅហាល។ បើធ្វះល្អគេជ្រលក់បែបនេះ តែពីរលើកបានសម្រេចតែម្ដង។

៤. បើធ្វះមិនចូល

បើជ្រលក់ពីរលើកហើយ ធ្វះនៅតែមិនព្រមចូល គេត្រូវពិនិត្យរកមូលហេតុ ៖

A. បើពិនិត្យឃើញធ្វះមានជាតិប្រៃ គេត្រូវយកផ្ទៃចេកណាំវ៉ាទុំ បកសម្បកដាក់ត្រាំក្នុងទឹកធ្លះ។ លុះព្រឹកឡើង គេស្រង់យកផ្ទៃចេកដែលដាក់ត្រាំនោះចេញ ទើបគេយកគាតមកជ្រលក់ម្តងទៀត។

B. បើធ្វះមានជាតិសាប គេត្រូវចាក់ទឹកក្បុងនិងទឹកកំបោរ បញ្ចូលលាយនឹងធ្វះបន្ថែមទៀត។

C. បើធ្វះជាតិប្រៃល្មមហើយ គេមិនចាំបាច់ត្រាំផ្ទៃចេកណាំវ៉ាទុំ ឬចាក់ទឹកក្បុងទឹកកំបោរបន្ថែមទៀតទេ។ គេយកគាតជ្រលក់ជាលើកទី០៣ តែម្តងជាការស្រេច។

*កំណត់សម្គាល់*

បើធ្វះល្អ គេជ្រលក់តែពីរលើកទេ បានសម្រេចហើយ។

បើធ្វះល្អមែនទែន គេជ្រលក់តែពីរលើកចង់ខ្មៅជ្រុល។

*សូមបញ្ជាក់ថា*

- សូត្រពណ៌ ស ជ្រលក់ល័ក្តធ្វះ ទៅជាពណ៌ខៀវ។
- សូត្រពណ៌ លឿង ជ្រលក់ល័ក្តធ្វះ ទៅជាពណ៌បៃតង។
- សូត្រពណ៌ ក្រហម ជ្រលក់ល័ក្តធ្វះ ទៅជាពណ៌ខ្មៅ។

## VIII. វិធីរៀបចំសូត្រផ្ទៃ

សរសៃសូត្រដែលគេយកទៅអន្ទង គេហៅថាសរសៃសូត្រផ្ទៃ (សរសៃផ្ទៃ, សូត្រផ្ទៃ)។ សូត្រផ្ទៃនេះ គេយកសរសៃសូត្រលេខ០១ ទៅក្ងួបជាពីរសសៃ រុំព័ទ្ធបំពង់ខ្នារ។ គេចាប់ទាញសរសៃសូត្រក្ងួបគ្នានោះ រវៃវេញឲ្យខ្នាញ់ល្មម ទាញបញ្ចូលទុកក្នុងកុង។ កាលបើគេក្ងួប និងគេរវៃវេញឲ្យខ្នាញ់ បានគ្រប់ចំនួននឹងចាប់អន្ទងបានហើយ គេត្រូវយកសូត្រនេះទៅរៀបចំបែបនេះ ៖

*ក. ប្រមោកនឹងទឹកក្បុង*

គេយកសូត្រដែលគេក្ងួប-ក្រនៀវធ្វើជាសូត្រផ្ទៃនោះ ទៅប្រមោកនឹងទឹកក្បុង (ពិធីធ្វើទឹកក្បុងនិងពិធីប្រមោកមាននិយាយក្នុងខាងដើមត្រង់ទំព័រ ៤០)។ គេយកសូត្រនោះទៅលាង ឲ្យទាល់តែជ្រះសម្បកស្អាតល្អ លែងមានជាតិរអិល ទើបគេយកសូត្រផ្ទៃទៅហាលឲ្យស្ងួត។

*ខ. វិធីជ្រលក់សូត្រផ្ទៃ*

វិធីជ្រលក់សូត្រផ្ទៃនេះ ពីបុរាណគេជ្រលក់យកពណ៌០២បែបគឺ ផ្ទៃក្រហម ឬផ្ទៃខ្មៅ។

១. ផ្ទៃក្រហម

បើគេស្រលាញ់ផ្ទៃក្រហម គេយកសូត្រផ្ទៃគឺសូត្រអន្ទងនោះ ទៅជ្រលក់ល័ក្តខ្មែរតែម្តង។ ឯពិធីជ្រលក់នេះ មានលក្ខណៈដូចគ្នានឹងពិធីជ្រលក់គាតដែរ។

២. ផ្ទៃខ្មៅ

បើគេស្រលាញ់ផ្ទៃខ្មៅវិញ គេយកសូត្រដែលជ្រលក់ល័ក្តខ្មែរហើយនោះ ទៅជ្រលក់ និងល័ក្តធ្វុះម្តងទៀត។ ពិធីជ្រលក់ល័ក្តធ្វុះម្តងនេះ ក៏មានមានលក្ខណៈអ្វីប្លែកគ្នា ពីពិធីជ្រលក់គាតដែរ។

សូមបញ្ជាក់ថា វិធីជ្រលក់សូត្រផ្ទៃនេះ គេច្រើនតែយកទឹកល័ក្ត ដែលនៅសល់ពីការជ្រលក់គាតនោះ យកមកជ្រលក់សូត្រផ្ទៃម្តងទៀត។ គេមិនបាច់យកទឹកល័ក្តថ្មី មកជ្រលក់ឡើយ។ ការធ្វើបែបនេះជាធម្មតាអ្នកធ្វើហូលតាំងពីបុរាណមក។ តែបើអ្នកធ្វើគេចង់បានពណ៌ល្អ ក៏អាចមានយកទឹកល័ក្តថ្មីមកជ្រលក់ដែរ តែមានតិចណាស់ស្ទើរតែគ្មាន។

<u>គ. វិធីឲ្យបាយសូត្រផ្ទៃ</u>

គេយកអង្ករល្អទៅបបរឲ្យល្វយ ហើយគេយកប្រេងដូង និងប្រេងកាតទៅចាក់ក្នុងផ្ទាំងបបរឲ្យល្អម។ គេយកស្បៃ ទៅត្រងចម្រោះយកបបរថ្លា។ គេយកសូត្រផ្ទៃដែលគេហាលឲ្យស្ងួតនោះមកជ្រលក់ ច្របាច់ ញី និងបបរថ្លានោះ ឲ្យបានជ្រួតជ្រាបចូលសព្វសាច់។ កាលបើទឹកបបរចូលជ្រាបសព្វសាច់ហើយ គេចាប់ពួតសូត្រនោះ ហើយគេបោកកន្ទ្រាក់ៗ ធ្វើឲ្យសរសៃសូត្រសសោះដាច់ចេញសរសៃពីគ្នា។ ទើបគេយកសូត្រ ទៅសំដិលឲ្យស្ងួតល្អ។

ការចាក់ប្រេងដូងនិងប្រេងកាតក្នុងទឹកបបរ សម្រាប់ធ្វើឲ្យសរសៃសូត្រមានពណ៌រលោងល្អផង កុំឲ្យស្រមោចរោមសរសៃសូត្រផង។

<u>ឃ. ខារដាក់បំពង់</u>

គេយកសូត្រផ្ទៃទាំងប៉ោយ ទៅពាក់ដាក់ក្នុងរងើង។ គេយកបំពង់ខារមកញាត់ក្នុងព្រលួតរហាត់ខារ (ក្អឿយ)។ គេរវៃទាញសរសៃសូត្រ បង្វិលជុំវិញបំពង់ខារ ធ្វើឲ្យបំពង់ខារពេញល្អដោយសូត្រ។ បើគេរវៃសូត្រព័ទ្ធជុំវិញបំពង់ខារ បានចំនួន២០ បំពង់បានចំនួន ៣០បំពង់ ឬបានចំនួន៤០បំពង់ (គេច្រើនយក៤០បំពង់ស្មើ ចំនួន០១ប្អូន) គេរៀបគេអន្ទង។

សូមបញ្ជាក់ថាសព្វថ្ងៃនេះ គេធ្វើរហាត់ខារពាក់កណ្តាលស្វ័យប្រវត្តិ អាចខារសូត្រម្តងបានចំនួន៤០បំពង់ក៏បាន។

សូមពិនិត្យមើលរូបនៅលេខ IV វិធីក្រនៀវ ត្រង់អក្សរ ក. វិធីស្រាវដាក់បំពង់។

*ង. ឈើអន្ទង*

*ឈើសម្រាប់អន្ទងសូត្រ មានមេសំដូក មេទទឹង កូន (ធ្មេញ) ចាប់ការ ៖*

*១. **មេសំដូក** គឺកំណាត់ឈើដែលមានមុខកាត់០៤ជ្រុង ឬ០៤ជ្រុងទ្រវែង ០,០៤ x ០,០៥ ឬ ០,០៤ x ០,០៥ ប្រវែង ០៣មទៅ០៤ម។ ឈើនេះ សម្រាប់ស៊កភ្ជាប់ទៅនឹងមេទទឹងចំ កណ្ដាលទាំងសងខាង។ គេធ្វើស្នៀត សម្រាប់សៀតបោះឲ្យណែនជាប់។*

*២. **មេទទឹង** គឺឈើ០២កំណាត់ដែលមានមុខកាត់ ០,០៦ម x ០,១២ម ប្រវែងប្រហែលជា ០១ម២០។ ឈើកំណាត់នីមួយៗនោះ នៅពីលើគេខួងរន្ធចំនួន១៤ ឬ១៨ សម្រាប់ដោតឈើមូលធ្វើជាធ្មេញអន្ទង។ ឈើមូលដោតភ្ជាប់ពីលើកំណាត់ឈើខ្ទីនីមួយៗនេះ គេហៅថាកូនអន្ទងស្រុកខ្លះហៅថាធ្មេញអន្ទង។*

*៣. **ចាប់ការ** គឺឈើសំប៉ែតខ្ទីដែលមានមុខកាត់ប្រហែលជា ០,០១ម x ០,០៧ ប្រវែងប្រហែលជា០១តឹកកន្ទះ (០,១៥) ចំនួន០២កំណាត់។ គេខួងចោះចុងឈើសំប៉ែតទាំងសងខាង។ ម្ខាងគេដោតភ្ជាប់នឹងឈើមូល ធ្វើជាធ្មេញចាប់ការ។ ឯម្ខាងទៀត គេខួងឲ្យមានរន្ធធំជាងឈើកូនអន្ទងសម្រាប់យកទៅស៊កនឹងកូនអន្ទង អាចបង្វិលបាន នៅក្នុងកូនអន្ទងតែម្ខាង។*

*សូមបញ្ជាក់ថា ចាប់ការទាំង០២នេះ ត្រូវនៅខាងចុងសូត្រអន្ទងទាំងសងខាង។ ចាប់ការម្ខាងគេចាប់សរសៃសូត្រ ធ្លាក់ខ្សែ១សរសៃម្ដង រៀងតាមសរសៃ សម្រាប់ស៊កពន្ធដាម។ ឯម្ខាងទៀត គេចាប់ធ្លាក់ខ្សែដែរ តែចាប់ធ្លាក់ខ្សែទាំង២០សរសៃ ទាំង៣០ សរសៃ ឬទាំង ៤០ សរសៃតែម្ដង តាមចំនួនបំពង់សូត្រសម្រាប់ស៊កពន្ធមូល។*

*ច. ស្នូអន្ទង*

*ឈើនេះ ជាឈើមូលប៉ែកខាងលើ សំប៉ែតជ្រុងប៉ែកខាងក្រោម ឬក៏ជាឈើមូលតែម្ដងនឹងមានភាពរលោងរអិល មិនអាចមានអ្វីទាក់បានឡើយ។ ឈើនេះ មានប្រវែងប្រហែលជា០២ម ទៅ០៣ម។*

*នៅប៉ែកខាងលើនៃឈើនោះ គេខៃរន្ធតូចៗនៅក្បែរគ្នា ទើបគេបង្កុងដែកមានរាងព្រះច័ន្ទពាក់កណ្ដាលយកមកស៊កភ្ជាប់នឹងឈើនោះ ជាច្រើនបង្កុង មានរហូតដល់៤០បង្កុង សម្រាប់យកសរសៃសូត្រផ្ទៃនៃបំពង់នីមួយៗ មកដាក់ទាញស្រាវតាមដែកបង្កុងនោះកុំឲ្យសរសៃសូត្រប៉ះគ្នា អាចជំពាក់គ្នាបាន។*

ឆ. អន្ទង់

គេយកសរសៃសូត្រដែលចេញតាមដែកបង្កុងនោះ មកបំពាក់ឆ្វាក់ខ្វែងរៀងគ្នា តាមសរសៃសូត្រនឹងឈើចាប់ការ ទុកសម្រាប់ស៊កពន្ធដាមៗ គេចាប់សរសៃសូត្រទាំងអស់នោះអូសយកទៅពាក់នឹងឈើកូនអន្ទង់ តាមការចង់បានវែង ឬខ្លីតាមការលែលកប្រវែងហូល និងចំនួនហូលដែលខ្លួនចង់បានៗ កាលបើទាញអូសដល់ឈើចាប់ការម្ខាងទៀត គេត្រូវរៀបឆ្វាក់ខ្វែងសរសៃសូត្រដែរ តែត្រូវឆ្វាក់ខ្វែងសរសៃសូត្រទាំងអស់តែម្តង សម្រាប់ស៊កពន្ធដាមៗ គេចាប់សរសៃសូត្រទាំងអស់ ទាញអូសចុះឡើង រហូតដល់បានគ្រប់ចំនួននៃ សេចក្តីត្រូវការ គឺចាប់ពីចំនួនសរសៃសូត្រ ៥៣ប្ដូន រហូតដល់៧០ប្ដូន តាមការចង់បាន ទទឹងហូលតូច ឬធំៗ

ជ. ក្តារមួរ

ក្តារមួរនេះ មានមុខកាត់០៤ជ្រុងទ្រវែង ប្រវែងទោល០២ធឹង (០,០២) បន្ទារប្រហែលជាង០២តឹក (០,២០) បណ្តោយប្រវែងប្រហែលជា០១ម៦០ ទៅ១ម៧០ៗ ទោលមានរាងខូង កណ្តាល (ទោលផ្ទារ) សម្រាប់ដាក់ផ្តប់ពន្ធមូល បង្កប់នឹងក្តារមួរ រុំមួរសូត្រអន្ទង់ៗ រូបនេះគេកំពុងរៀបចំសរសៃសូត្របញ្ចូលក្តារមួរ ដោយអ៊ុំស្រី ស៊ុន សាលី, នាង នុត សុគ្គាៗ

ឈ. បន្ទូរតង្កៀ

មុននឹងមួរសូត្របញ្ចូលក្តារមួរ គេយកបន្ទូរតង្កៀពីរ ដែលគេធ្វើអំពីឈើ ឬឫស្សីមូលតូចមានភាពរលោង យកមកស៊កដឹកនាំមុខសូត្រ ក្នុងពេលមួរសូត្របញ្ចូលក្តារមួរៗ

ញ. ធ្មេញឈើ

គេបិតឫស្សីធ្វើជាបន្ទះល្អិតស្តើងឆ្មារ តែមានសាច់រឹង ឬគេធ្វើអំពីសរសៃដេលស្តើងឆ្មារល្អិតប្រវែងប្រហែលជា០៤ធ្នាប់ៗ គេយកបន្ទះឫស្សីតូចល្អិត ០៦សរសៃ គឺម្ខាង០៣ សរសៃប្រវែងប្រហែលជា០១ម២០ ទៅ០១ម៣០ ហើយយកខ្សែអំបោះមកធ្វាក់ស្រេះចងគាបនឹងទប់ក្បាល រឹតភ្ជាប់បន្ទះឫស្សី ឬបន្ទះដែក ឲ្យតឹងទាំងសងខាង ធ្វើជាធ្មេញឈើ សម្រាប់ទាញគោះសរសៃសូត្រឲ្យខិតជិតជាប់គ្នាៗ

ដ. ចាក់ធ្មេញឈើ

មនុស្សពីរនាក់ ម្នាក់ដៃម្ខាងកាន់ធ្មេញឈើ ឯដៃម្ខាងទៀត (ដៃស្តាំ) កាន់ធ្មេញកណ្តូបដែលធ្វើអំពីបន្ទះស្នែង របន្ទះឫស្សីស្តើងសំប៉ែត មានផ្សៀងសម្រាប់ចាក់ផ្តក់ទាញសរសៃសូត្រៗ គេចាក់តាម

លំដាប់ចន្លោះធ្មេញឈើរៀងគ្នា។ ម្នាក់ទៀត ចាប់កាន់សរសៃសូត្រ យកមកពាក់នឹងធ្មេញកណ្ដូប តាមលំដាប់សរសៃសូត្ររៀងគ្នា និងតាមផ្នែកខាងលើនិងខាងក្រោម។

កាលបើម្នាក់យកសរសៃសូត្រ មកបំពាក់នឹងជឿងធ្មេញកណ្ដូបហើយ ម្នាក់ដែលកាន់ធ្មេញកណ្ដូប ទាញផុតធ្មេញឈើ ប្រមូលយកសរសៃសូត្រមកដាក់នឹងកធ្មេញកណ្ដូប។ ទើបគេចាប់ចាក់ចន្លោះធ្មេញឈើ ជាបន្តបន្ទាប់ទៅទៀត។ លុះគេចាក់ទាញយកសរសៃសូត្រប្រមូលសរសៃសូត្របានច្រើនហើយ ទើបគេដោះចេញម្ដង ហើយគេយកអ្វីមកចងទុក០១ដុំតាមផ្នែកលើ ផ្នែកក្រោម ទើបគេចាប់ចាក់ទាញបន្តទៅទៀត។ ការធ្វើបែបនេះ រហូតដល់អស់សរសៃសូត្រផ្ទៃ។

លុះអស់សរសៃសូត្រផ្ទៃហើយ គេយកសូត្រទាំងនោះមកស៊កឈើធ្នាម (ស្រុកខ្លះហៅស្នាម) តាមលើតាមក្រោម។ គេកាសសរសៃឲ្យស្មើគ្នា គេស៊កធ្នាមផ្គប់ភ្ជាប់ក្នុងផ្សុំ ឬដាក់ភ្ជាប់នឹងកន្ទះផ្សុំ។

ឋ. ឈើផ្សុំ

ឈើផ្សុំនេះ មានបណ្ដោយប្រវែងប្រហែលជា១,៦០ម ទៅ១,៧០ម មានមុខកាត់០២ជ្រុងស្មើក្នុង០១ជ្រុងប្រវែងប្រាំធ្នឹង (០,០៥ម)។ នៅតាមអែបជាយបណ្ដោយឈើផ្សុំ គេដាប់មុខ ០១ធ្នឹង សម្រាប់ផ្គប់សង្កត់សូត្រឲ្យជាប់ដោយធ្នាម ឬបង្គប់ភ្ជាប់ដោយកន្ទះ។ ពេលត្បាញសំពត់ហូលបានល្មមនឹងមូរ គេមូរសំពត់ហូលរុំព័ទ្ធឈើផ្សុំ។

កាលបើគេចាក់ធ្មេញឈើបញ្ចូលសរសៃសូត្របានអស់ហើយ គេយកក្ដារមូរដែលពេញដោយសរសៃសូត្រ ទៅដាក់ផ្កាប់លើកី ដើម្បីទាញរឹតសរសៃសូត្រឲ្យតឹង រៀបចំនឹងចូរសូត្រ។

ឌ. កី

កីពីបុរាណ គេធ្វើបែបនេះ៖

១. មានមេសណ្ដូកធំពីរនៅខាងក្រោម ដែលមានបណ្ដោយប្រហែលជា០៥ម៉ែត្រ ទៅ០៦ម៉ែត្រ។ មេសណ្ដូកខាងក្រោមនេះ មានមុខកាត់តូចណាស់ ០,០៥ម x ០,១២ម។ មេ សណ្ដូកជួរលើ មានមុខកាត់ ០,០៥ម x ០,០៨ម។ នៅប៉ែកខាងក្រោយ គេដាប់មេសណ្ដូក៖

- ពីលើ គេដាប់ដាក់មេបញ្ឈរ សម្រាប់ធ្វើជាទម្រកន្លែងអង្គុយផង សម្រាប់ដាក់ឈើស្នូរទ្រឈើភផង។
- ពីខាង គេដាប់ដាក់មេទទឹង។
- ពីលើ ប្រវែង ០១ភាគ០៣ ពីក្រោយ គេដាប់ដាក់មេបញ្ឈរ សម្រាប់ជាទម្រមេសណ្ដូកលើផង សម្រាប់ដាក់ឈើស្នូរទ្រឈើភផង។

- ពីលើ ចម្ងាយពីក្រោយប្រហែលជា ០,៧០ម គេដាប់ដាក់ឈើកកី សម្រាប់ទ្រឈើផ្សំ។
- ពីលើ ប៉ែកខាងចុង (ខាងមុខ) គេដាប់ដាក់ឈើទប់សម្រាប់ឈើរឹតផង សម្រាប់ទ្រចុងមេសណ្ដូកលើផង។
- ពីខាង គេដាប់ដាក់មេទទឹង។

កាលបើគេយកក្ដារម្ងូរ មកដាក់ផ្កាប់លើមេសណ្ដូកលើហើយ គេយកឈើផ្សំមកដាក់លើបង្គាបកកីហើយ គេយកក្ដារត្រដោកមកប្រហាកបញ្ចូលក្ដារម្ងូរ។

ឃ. ក្ដារត្រដោក

ក្ដារត្រដោក គឺឈើ ឬឫស្សីពីរកំណាត់ មានប្រវែងប្រហែលជា០១គក់។ គេដាប់ឈើឬឫស្សីនោះនៅចំកណ្ដាល ប្រវែងប្រហែលជាពីរតឹកកន្ទះ (០,២៥ម) សម្រាប់ប្រហាកបញ្ចូលក្ដារម្ងូរម្ខាងម្ដងៗ។ នៅខាងគល់ក្ដារត្រដោក គេចោះប្រហោងសម្រាប់ស៊កខ្សែចង បង្កងមូលសម្រាប់ស៊កឈើរឹត។

ណ. ឈើរឹត

ឈើរឹត គឺជាឈើ ឬឫស្សីមូលក៏បាន ជ្រុងក៏បាន តែមានភាពរឹងមាំ សម្រាប់យកទៅស៊កបញ្ចូលក្នុងខ្សែបង្កងមូលគល់ក្ដារត្រដោក និងយកខ្សែ០១វែងមកចងរឹតកណ្ដាលឈើរឹតភ្ជាប់នឹងឈើមេទទឹងចុងកី ដើម្បីធ្វើឲ្យសរសៃសូត្រផ្ទៃ លាតសន្ធឹងតឹងសាច់ស្មើ។ កាលបើសូត្រផ្ទៃតឹងសាច់ស្មើហើយ គេត្រូវយកក្ដារកីមកដាល់លើមេសណ្ដូកលើ សម្រាប់អង្គុយ។ ឈើរឹត កំណាត់ឈើដែលព័ទ្ធខ្សែរឹតនៅលើចុង។

ត. ក្ដារកី

ក្ដារកី គឺជាក្ដារសំខាន់ទ្រាប់អង្គុយត្បាញ ដែលមានមុខកាត់ ០,០៣ម x ០,២០ម ឬ ០,២៥ម, បណ្ដោយប្រវែងប្រហែល ១,៥០ម។ ក្ដារកីនេះ គេដាក់អង្គុយនៅប៉ែកក្រោយកី។ ពេលចាប់ថ្កុរ ត្រូវរកខ្សែតង្កុរ ទល់ថ្កុរ, ក្ដារតង្កុរ, ឈើឈ្នាន់, ឈើព, គម្របធ្មេញឈើ, រ៉ត ឬឈើចាងណាង។

ថ. ខ្សែតង្កុរ

ខ្សែតង្កុរ គឺជាខ្សែអំបោះដែលគេវេញឲ្យខ្មាញ់ ហើយមានប្រវែងវែង។ ខ្សែអំបោះវេញ មានប្រវែងវែងនេះ សម្រាប់យកមកចងធ្វាក់ខ្វែងរុំព័ទ្ធសរសៃសូត្រផ្ទៃភ្ជាប់នឹងទល់តង្កុរ។ ការធ្វាក់ខ្វែងបែបនេះហៅថា ថ្កុរសូត្រ។

មុននឹងយកខ្សែតង្កៃរមកថ្ករសូត្រ គេត្រូវយកខ្សែតង្កៃរនោះទៅឲ្យបាយ ធ្វើឲ្យសរសៃអំបោះខ្សែតង្កៃរនេះ រឹងស្រួលទាញថ្ករ។ មុននឹងឲ្យបាយ គេយកកុងមករវៃទាញសរសៃតង្កៃរចេញពីបំពង់បញ្ចូលរុំព័ទ្ធកុងធ្វើជាប៉ោយដើម្បីស្រួលឲ្យបាយ។

ទ. ទល់តង្កៃរ

ទល់តង្កៃរនេះ គេធ្វើអំពីឫស្សី ឬឈើតូចមូលត្រង់រឹង សម្រាប់យកមកធ្វើជាឆ្អឹងទាញសរសៃសូត្រផ្ទៃឲ្យចុះ ឬឲ្យឡើងដើម្បីឲ្យមានប្រលោះបោះត្រល់បញ្ចេញបញ្ចូលតាមនោះបាន មានចំនួន ០៦លើ និង០៦ក្រោម រួមជា១២ដើម។

ធ. ក្តារតង្កៃរ

ក្តារតង្កៃរនេះ គឺបន្ទះក្តារមួយកំណាត់មានបន្ទារប្រហែលជា០១តឹក (០,១០ម), មានទោលប្រហែលជា០១ធ្នឹង (០,០១ម) មានប្រវែងប្រហែលជា ០,២០ម។ បន្ទះក្តារនេះ គេយកទៅឈូសខាត់ឲ្យរលោងស្អាត។ ប៉ែកពាក់កណ្តាលមកក្រោយ គេធ្វើឲ្យមានរាងទាបជំរៀលជាងប៉ែកខាងមុខបន្តិច។ ការធ្វើបែបនេះ ដើម្បីឲ្យមានភាពស្រួលខិតបង្កិលក្តារតង្កៃរទៅមុខជា លំដាប់។ ក្តារតង្កៃរនេះ គេយកមកធ្វើជាពុម្ព ចងរុំព័ទ្ធតង្កៃរភ្ជាប់សរសៃសូត្រទៅនឹងឈើទល់តង្កៃរទាំងពីរ កុំឲ្យខ្សែតង្កៃរមានទាបមានខ្ពស់។

ន. ឈើឈ្នាន់

នៅប៉ែកខាងក្រោម គេចងកំណាត់ឈើមូល០៣កំណាត់សម្រាប់ជាន់ មានបណ្តោយប្រហែលជា០៨តឹក (០,៨០ម) មុខកាត់មានអង្កត់ផ្ចិត (វិជ្ឈមាត្រ) ប្រហែលជាពីរធ្នឹង (០,០២ម)។ ពីបុរាណនៅចុងឈើឈ្នាន់ទាំងសងខាង គេក្រលឹងធ្វើជាក្បាច់រំលេចផ្សេងៗ គួរឲ្យចាប់អារម្មណ៍ គេចងខ្សែចុងឈើឈ្នាន់ទាំងសងខាង ភ្ជាប់ទៅនឹងទល់តង្កៃរ។ ការចងភ្ជាប់ឈើឈ្នាន់នឹងទល់តង្កៃរនេះ គឺឈើឈ្នាន់មួយចងភ្ជាប់នឹងទល់តង្កៃរមួយគូ។ ឈើឈ្នាន់០៣ចងភ្ជាប់នឹងទល់តង្កៃរ០៣គូ។ ឈើ០៣កំណាត់ នៅក្រោមជើងលោកយាយ ខុម នេះហើយ ដែលគេហៅថាឈើឈ្នាន់។

ប. វិធីថ្ករ

បើយោងទៅតាមការឃើញ និងតាមការសាកសួរអំពីវិធីថ្ករ មានការប្លែកពីគ្នា។ តែបើយោងទៅលើពិធីធ្វើ មិនមានការប្លែកគ្នាឡើយ។

ក. បើតាមការឃើញ គេថ្ករនៅឃុំព្រៃកចង្រ្កាន ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែងមាន មនុស្ស០២នាក់ ម្នាក់អ្នកចាប់រើសសរសៃសូត្រ, ឯម្នាក់ទៀតអ្នកចាប់ទាញសរសៃខ្សែតង្ករធ្វាក់ទៅនឹង សរសៃសុត្រ ដែលគេរើសហុចឲ្យនោះ ភ្ជាប់ទៅនឹងទល់តង្ករទាំងគូរ។

ខ. នៅស្រុកបាទី ខេត្តតាកែវ គេធ្វើពន្ធដាមបញ្ចោត០៣។ គេត្រូវរើសសរសៃសូត្រផ្ទៃ (អន្ទង) បញ្ចូលពន្ធដាមបញ្ចោតបែបនេះ ៖

- ពន្ធដាមបញ្ចោតទី០១ គេត្រូវរើសសរសៃសូត្រដាក់ពន្ធដាម តាមពិធីលើកទី០១ សង្កត់ ០២ គឺលើកសរសៃសូត្រទី០១ ទី០៤ ទី០៧ ... សង្កត់សរសៃសូត្រទី០២, ០៣ ទី០៥, ០៦, ទី០៨, ០៩ ...។
- ពន្ធដាមបញ្ចោតទី០២ គឺលើក០១សង្កត់០២ដែរ តែគេលើកសរសៃសូត្រទី០២, ទី០៥, ទី ០៨ ... សង្កត់សរសៃសូត្រទី០១, និងទី០៣, ០៤, ទី០៦, ០៧, ទី០៩, ១០ ... ។
- ពន្ធដាមបញ្ចោតទី០៣ គឺគេលើក០១សង្កត់០២ដែរ តែគេលើកសរសៃទី០៣, ទី០៦, ទី ០៩ ... សង្កត់សរសៃសូត្រទី០១, ០២, ទី០៤, ០៥, ទី០៧, ០៨, ទី១០, ១១ ...។

បើគេរើសសរសៃសូត្រដាក់ពន្ធដាមបញ្ចោតបានហើយ គេចាប់សរសៃសូត្រនៅលើពន្ធដាម បញ្ចោត តាមលំដាប់ យកមកធ្វាក់ខ្វែងភ្ជាប់នឹងទល់តង្ករ។ គេចាប់ថ្ករមុន គឺតង្ករខាងចុង ឬខាងក្រៅ។ បន្ទាប់មកគេចាប់ថ្ករតង្ករខាងដើម ឬខាងក្នុង។ ចុងក្រោយគេចាប់ថ្ករតង្ករ កណ្ដាល។

កាលបើគេថ្ករតង្ករខាងក្រោមបានហើយ គេចងខ្សែឈ្នាន់ភ្ជាប់នឹងទល់តង្ករទាំង០៣រួចទើប គេផ្ទារក្ដារមូរនឹងរឹតសន្ទឹងសរសៃសូត្រឲ្យតឹងស្មើដូចមុន ទើបគេចាប់ថ្ករតង្ករប៉ែកខាងលើទៀត។ វិធីចាប់ថ្ករប៉ែកខាងលើនេះ ក៏មានលក្ខណៈដូចវិធីថ្ករប៉ែកខាងក្រោមដែរ គ្រាន់តែធ្វាក់ខ្វែងសរសៃខ្សែ តង្ករទៅនឹងសរសៃសូត្រផ្ទៃឲ្យធ្វាក់ទាក់គ្នា សម្រាប់ទាញសរសៃសូត្រផ្ទៃឲ្យហាចុះ ឬហាឡើង តាម ការជាន់ឈ្នាន់។

<u>ផ. ឈើព</u>

ឈើពនេះ ជាឈើមូល ឬជ្រុង សម្រាប់យកមកគងលើស្នបណ្ដោយនៃដំបូលកី។ នៅសង ខាង តែខាងក្នុងដំបូលកីនៃឈើពនេះ គេចងខ្សែល្មមទម្លាក់មកក្រោម។ ចុងខ្សែខ្វីនេះ គេចងរ៉ែត ឬ ឈើមូលខ្វីបណ្ដោយប្រវែងប្រហែលជា០១តឹក០៣ធឹង (០,១៣ម) ធ្វើជាចាងណាង។

នៅចុងចាងណាងខាងមុខ គេបន្ទាយខ្សែវែងបន្តិច មកចងភ្ជាប់នឹងទល់តង្ករជួរមុខ។ នៅចុង ចាងណាងខាងក្រោយ គេចងបន្ទាយខ្សែខ្វី មកចងចំពាក់កណ្ដាលឈើចាងណាងមួយទៀត។ នៅ

ចុងសងខាងចាងណាងទៅ០២នេះ ម្ខាងគេចងភ្ជាប់នឹងទល់តង្កៀវជួរកណ្ដាល (ទី០២)។ ឯចុងចាងណាង ម្ខាងទៀត គេចងភ្ជាប់នឹងទល់តង្កៀវជួរក្រោយ (តង្កៀវ ជិតខ្លួន)។ ម្យ៉ាងទៀតគេមិនប្រើឈើចាងណាង ទេ គេប្រើឈើរ៉ែត ឬដែករ៉ែត។ ឯពិធីចងរ៉ែត ក៏មានលក្ខណៈប្រហែលនឹងឈើចាងណាងដែរ។

*ព. ពន្ធដាម*

ឈើ ឬឫស្សី មានសណ្ឋានជមសំប៉ែត សម្រាប់ស៊កខ្វាស់នាមុខសរសៃសូត្រផ្ទៃញែកមុខកុំឲ្យ ព័ន្ធគ្នា ហៅត្រឹមតែដាមក៏បាន។ ពន្ធដាមនេះ មានពីរបន្ទះសម្រាប់ខ្វាស់សូត្រ។

*ភ. ពន្ធមូល*

ឈើ ឬឫស្សីមូលមួយគូ សម្រាប់ស៊កខ្វាស់សូត្រ ដាក់បង្កប់ភ្ជាប់នឹងក្ដារមូរសរសៃសូត្រអន្ទង។

*ម. ចន្ទាល់*

ចន្ទាល់នេះ គឺជាប្រដាប់ស្ទាល់សាច់សំពត់ ដែលកំពុងត្បាញឲ្យតឹងសាច់ទទឹងកុំឲ្យរួចសាច់។ ចន្ទាល់នេះ ប្រវែងវែងជាងសាច់ទទឹងបន្តិច។ នៅចុងចន្ទាល់ទាំងសងខាងនេះ មានបន្ទា០២ ម្ខាង សម្រាប់ដោតនៅជាយរឹមសំពត់ទាំងសងខាង។ ចន្ទាល់នេះ គេខ្វាស់សាច់សំពត់ពីខាងក្រោម។

*យ. គម្របធ្មេញឈើ*

បន្ទះក្ដារពីរកំណាត់ មានបណ្ដោយប្រហែលជា១,៣០ម, មានទោលប្រហែលជា០១ធឹងកន្ទះ , បន្ទារប៉ែកបន្ទះខាងលើប្រហែលជា០១តឹក (០,១០ម), ប៉ែកខាងក្រោមប្រហែលជា០៣ធឹង (០,០៣ ម)។ ទោលនៅប៉ែកខាងលើ និងប៉ែកខាងក្រោម គេលកប្រវែងធ្មេញឈើ ឬវែងជាងធ្មេញឈើបន្តិច សម្រាប់ដាក់ធ្មេញឈើ។ នៅចុងកន្ទែងលកធ្មេញឈើទាំងសងខាងទាំងខាងលើ ទាំងខាងក្រោម គេ ដាប់ដំណាប់សម្រាប់ស៊កឈើធ្វើជាមេ ភ្ជាប់បន្ទះខាងលើ និងបន្ទះខាងក្រោមឲ្យជាប់គ្នា។

បន្ទះខាងលើនេះ ប៉ែកខាងខ្នង នៅខាងចុងទាំងសងខាង គេច្រើនខ្វៀលធ្វើជាក្បាច់រចនា អ៊ែន ឬងើប ឬក៏ឆ្លាក់ជារូបសត្វ តាមការស្រលាញ់របស់ជាងឈើ។ នៅប៉ែកកណ្ដាលគេខាត់ឲ្យមូល រលោងរលើប សម្រាប់កាន់ត្បាញ។

នៅប៉ែកបន្ទះខាងក្រោម ជួនកាលគេធ្វើជាក្បាច់រចនាផ្សេងៗ ឬគេដុសខាត់ឲ្យរលោងដែរ។ ពេលដាក់ធ្មេញឈើបញ្ចូលក្នុងគម្របធ្មេញឈើរួច គេត្រូវយកខ្សែចងធ្លាក់រឹតគម្របធ្មេញឈើទាំង សងខាង ភ្ជាប់ទៅនឹងឈើរាដែរ។

## IX. វិធីចាក់គោម

ពាក្យថា «គោម ឬគោមហូល» នេះ គឺជាក្បាច់រចនារបស់អ្នករៀបចំត្បាញហូល។ បើអ្នករៀបចំត្បាញហូល គេស្រលាញ់រូបអ្វី ឬគេស្រលាញ់ក្បាច់បែបណា គេត្រូវគូររូបនោះនិង រំលេចពណ៌តាមការស្រលាញ់ចូលចិត្តរបស់ខ្លួន។

កាលបើគេគូររូប និងការរំលេចពណ៌បានដូចបំណងហើយគេត្រូវយករូបដែលគេរំលេចពណ៌ហើយនោះ មកធ្វើជាគំរូ សម្រាប់ចងយកគាតដើម និងរៀបចំពណ៌តាមរូបគំនូរនោះ។

កាលបើគេចងគាត និងពណ៌ តាមគំរូគាតដើមបានហើយ គេត្រូវយកគាតនោះទៅជ្រលក់ តាមវិធីជ្រលក់គាត។ បើជ្រលក់គាតបានស្រេចហើយ គេត្រូវយកសូត្រគាតនោះទៅខ្នារបញ្ចូលខ្នារ។ គេយកខ្នារទៅដាក់បញ្ចូលក្នុងត្រល់ សម្រាប់ចាក់ត្បាញហូល។ បើការខារគាតដាក់មិនត្រឹមត្រូវតាមក្បួន ឬពេលត្បាញចាប់ខ្នារដាក់ក្នុងត្រល់មិនត្រឹមត្រូវតាមក្បួន ក៏គោមហូលនោះ មិនមានលក្ខណៈល្អឡើយ។ ដូចនេះ គេត្រូវប្រុងប្រយ័ត្នណាស់ក្នុងពេលខារសូត្រគាតដាក់ខ្នារផង ក្នុងពេលចាប់ខ្នារមកដាក់ក្នុងត្រល់ម្ដងៗមិនឲ្យច្រលំខ្នារផង។

<u>ក. វិធីខារសូត្រគាត</u>

កាលបើគេយកក្បាល (ព្រៃកចង្រ្កានហៅថា ក្បាល បាទីហៅថា បន្ទះ ឯស្រុកខ្លះទៀតហៅថា ប៉ោយ) តាមគំរូជុំណាមួយ មកដាក់ពាក់នឹងរង្វីង, គេយកខ្នារប្រហោង ឬឡូតមកស៊កនឹងដែកព្រលួតរហាត់ ឬខ្នារតាន់មកដាក់ព័ន្ធនឹងខ្សែរហាត់ រវៃទាញសរសៃសូត្រគាតចេញពីរង្វីង បញ្ចូលខ្នារ។

គេត្រូវខារក្បាលជុំគាតនោះឲ្យអស់ ទោះជាប៉ុន្មានខ្នារក៏ដោយ។ គេត្រូវចាប់ក្រងខ្នារតាមក្រុម គឺជុំក្បាលទី០១ ក្រងជុំទី០១, ជុំក្បាលទី០២ ក្រងជុំទី០២, ... ។ ការក្រងទុកនេះ មិនឲ្យច្រលំខ្នារទេ គឺចំណាំឲ្យច្បាស់។ បើច្រលំខ្នារគាត ដល់ពេលត្បាញ ចេញក្បាលខុសគោមមិនត្រូវ តាមបំណងរបស់ខ្លួនឡើយ។

សូមបញ្ជាក់ថា គោមណា ពេលត្បាញមានខ្នារ (ឡូត) ច្រើន ពេលចងសូត្រចុងមានកូនតិចៗ តែបើគោមណា ពេលត្បាញមានខ្នារតិច ពេលចងសូត្រចុង (ចងគាត) មានកូន ច្រើនទៅវិញ។ លោកយាយ អ៊ូ យីន កំពុងខារសូត្រគាត បញ្ចូលខ្នារ។

<u>ខ. វិធីត្បាញ</u>

មុននឹងចាប់យកខ្នារមកដាក់ក្នុងត្រល់ត្បាញ គេត្រូវយកខ្នារមករៀបចំ ក្រងចំណាំតាមលំដាប់។ បើមិនធ្វើដូចនេះទេ ពេលចាប់យកខ្នារមកដាក់ក្នុងត្រល់ម្ដងៗ អាចច្រលំខ្នារ។ បើ ច្រលំខ្នារ

ហើយ មិនអាចកើតបានជាគោម តាមគំរូដើមឡើយ។ ដូចនេះ គេត្រូវរៀបចំក្រងខ្នារ ឬតំរៀបខ្នារតាមលំដាប់ ដោយប្រុងប្រយ័ត្នណាស់។

ការត្បាញហូលតាមគោមនីមួយៗនោះ មានចំនួនខ្នារមិនដូចគ្នាទេ គឺការត្បាញហូលខ្លះមានក្បាលច្រើន តែប្រើខ្នារតិចៗ ឯការត្បាញហូលខ្លះវិញ មានក្បាលតិច តែប្រើខ្នារច្រើន។

ដើម្បីស្រួលចំណាំ យើងសូមរៀបចំនៃការត្បាញហូលជាក្រុម តាមការប្រើក្បាលសូត្រគាត និងការប្រើខ្នារ ពីព្រោះពិតមែនតែការត្បាញតាមគោមនីមួយៗមានលក្ខណៈនៃការប្រើក្បាលសូត្រគាត និងការប្រើខ្នារ មានចំនួនមិនដូចគ្នាមែន តែគង់មានការត្បាញហូលខ្លះ មានគោមខុសគ្នាមែន តែមានការប្រើក្បាលសូត្រគាត និងការប្រើខ្នារមានចំនួនដូចគ្នាបេះបិទដែរ។

ដូចនេះ យើងសូមបញ្ជាក់ថា បើចែកជាក្រុម តាមការប្រើក្បាលសូត្រគាត និងការប្រើចំនួនខ្នារ មានច្រើនក្រុមណាស់។ តែយើងសូមលើកក្រុមខ្លះៗមកបញ្ជាក់ជូនដូចតទៅនេះ ៖

ក្រុមទី០១. ការត្បាញហូល០១ ត្រូវប្រើសូត្រគាត០៥ក្បាល ក្នុងក្បាលគាតនីមួយៗមានចំនួនខ្នារ១០ រួមខ្នារទាំងអស់៥០ខ្នារ ដូចជាហូលៈ

១. គោមស្លឹកកញ្ចប់

............................

............................

ក្រុមទី០២. ការត្បាញហូល០១ ត្រូវប្រើសូត្រគាត០៤ក្បាល ក្នុងក្បាលគាតនីមួយៗមានចំនួនខ្នារ ១៣ រួមខ្នារទាំងអស់៥២ខ្នារ ដូចជាហូលៈ

១. គោមបួនយ៉ាង

២. គោមក្តិបសណ្តាន់

៣. គោមផ្កាប្រាក់គ្រាប់ឃ្មោក

៤. គោមប៉ូចកាក់ភ្នែកគោ

៥. គោមកូនហ៊ីង

៦. គោមផ្កាម្ទិះជរជើង

៧. គោមក្អក់ផ្កាម្ទិះគោមធំ

៨. គោមគ្រាប់ឃ្មោក

៩. គោមផ្កាយព្រឹក

១០. គោមផ្កាផ្គុលខ្មែរ

............................

............................

ក្រុមទី០៣. ការត្បាញហូល០១ ត្រូវប្រើសូត្រគាត០៣ក្បាល ក្នុងក្បាលគាតនីមួយៗមានចំនួនខ្នារ ១៥ រួមខ្នារទាំងអស់៤៥ខ្នារ ដូចជាហូល:

១. គោមផ្កាវីកជរជើង

២. គោមផ្កាចន្ទជរជើង

............................

............................

ក្រុមទី០៤. ការត្បាញហូល០១ ត្រូវប្រើសូត្រគាត០៣ក្បាល ក្នុងក្បាលគាតនីមួយៗមានចំនួនខ្នារ ១៦ រួមខ្នារទាំងអស់៤៨ខ្នារ ដូចជាហូល:

១. គោមកន្ទង់កូលាប

២. គោមកូលាប

............................

............................

ក្រុមទី០៥. ការត្បាញហូល០១ ត្រូវប្រើសូត្រគាត០៣ក្បាល ក្នុងក្បាលគាតនីមួយៗមានចំនួនខ្នារ ១៧ រួមខ្នារទាំងអស់៥១ខ្នារ ដូចជាហូល:

១. គោមខ្មែរបែតង

២. គោមក្អក់កូនសោ

៣. គោមបន្ទាខ្នុរ ឬផ្កាម្ទិះ

៤. គោមប៉ូចកាក់ជរជើង

៥. គោមក្អក់ពីងពាង

៦. គោមក្អក់សម័យ

៧. គោមដបតៃ

៨. គោមគ្រាប់ម្រះ

៩. គោម RX

១០. គោមប៉ូចកាក់សុទ្ធ

១១. គោមប្រញាំជើងមាន់

១២. គោមផ្កាម្រេច

១៣. គោមដែរហាត់

១៤. គោមក្អក់សារពើ

............................

............................

ក្រុមទី០៦. ការត្បាញហូល០១ ត្រូវប្រើសូត្រគាត០៣ក្បាល ក្នុងក្បាលគាតនីមួយៗមានចំនួនខ្នារ ១៩ រួមខ្នារទាំងអស់៥៧ខ្នារ ដូចជាហូល:

១. គោមក្តិបខ្នុរ

............................

............................

ក្រុមទី០៧. ការត្បាញហូល០១ ត្រូវប្រើសូត្រគាត០៣ក្បាល ក្នុងក្បាលគាតនីមួយៗមានចំនួនខ្នារ ២១ រួមខ្នារទាំងអស់៤២ខ្នារ ដូចជាហូល:

១. គោមមេអំបៅ

............................

............................

ក្រុមទី០៨. ការត្បាញហូល០១ ត្រូវប្រើសូត្រគាត០៣ក្បាល ក្នុងក្បាលគាតនីមួយៗមានចំនួនខ្នារ ២៣ រួមខ្នារទាំងអស់៤៦ខ្នារ ដូចជាហូល:

១. គោមក្អក់ជើងម៉ា ឬក្អក់ល្ហោន

............................

............................

ក្រុមទី០៩. ការត្បាញហូល០១ ត្រូវប្រើសូត្រគាត០៣ក្បាល ក្នុងក្បាលគាតនីមួយៗមានចំនួនខ្នារ ២៥ រួមខ្នារទាំងអស់៥០ខ្នារ ដូចជាហូល:

១. គោមក្តិបខ្នុរ

២. គោមភ្នែកគោ

៣. គោមធំក្បាលព្រហ្ម

៤. គោមក្លោកពង់

៥. គោមផ្កាយព្រឹកជរជើង

៦. គោមផ្កាប្រាក់

៧. គោមផ្កាយព្រឹក

៨. គោមក្លោកឈរ

៩. គោមក្អក់ជើងម៉ាផ្កាយព្រឹក

១០. គោមភ្នែកគោផ្កាយព្រឹក

១១. គោមក្អក់ផ្កាផ្កុល

១២. គោមសត្វហង្ស

............................

............................

ក្រុមទី១០. ការត្បាញហូល០១ ត្រូវប្រើសូត្រគាត០៣ក្បាល ក្នុងក្បាលគាតនីមួយៗមានចំនួនខ្នារ ៣៣ រួមខ្នារទាំងអស់៩៩ខ្នារ ដូចជាហូល:

១. គោមសញ្ញាផ្ទះពេទ្យ

............................

............................

## X. ការរៀបចំបង្ហាញគោមហូល

ការដាក់បង្ហាញគោមហូលនីមួយៗនេះ ខ្ញុំមិនបានរៀបចំតាមលក្ខណៈណាមួយដោយដាច់ខាតទេ គឺខ្ញុំរៀបចំដាក់បង្ហាញតាមតម្លៃអាយុនៃហូលនីមួយៗផង តាមតម្លៃក្បាច់គោមដែលខ្ញុំយល់ថាល្អផង។

ហូលគោមផ្កាយព្រឹកផ្កាម្ទេសនេះ ជាហូលមានប្រវត្តិច្រើនតំណមនុស្សមកហើយ។ បើគិតតាមតំណមនុស្ស ហូលនេះមានអាយុជិត១៤០ឆ្នាំ ឬក៏១៥០ឆ្នាំជាងផងក៏មិនដឹង។ តាមដំណើរប្រវត្តិពេលយាយនៅ រៀបអាពាហ៍ពិពាហ៍ជាមួយតាសំ នៅឆ្នាំឆ្លូវ គ.ស.១៨៥៣ ក្នុងព្រះជន្មាយុ២០ឆ្នាំ លោកយាយជាម្ដាយលោកយាយនៅ បានប្រគល់ហូលនេះឲ្យយាយនៅស្លៀក ក្នុងពេលរៀប

*អាពាហ៍ពិពាហ៍ តែមិនបានដឹងថាម្ដាយលោកយាយនៅ គាត់ត្បាញក្នុងពេលផ្ទាំរៀបអាពាហ៍ពិពាហ៍ ឬគាត់បានត្បាញទុកយូរហើយទេ។*

*លុះដល់ឆ្នាំជូត គ.ស. ១៩២៤ ក្នុងព្រះជន្មាយុ ៩១ឆ្នាំ លោកយាយនៅ បានប្រគល់ហូលនេះឲ្យទៅតាចេងជាប្អូនពៅរបស់គាត់។ តែតាចេង គាត់គ្មានប្រពន្ធគាត់យកហូលនេះទៅចងដៃ នាងគឹម ហ៊ន់ ជាក្មួតសម្ងាញ់របស់គាត់ ក្នុងពេលរៀបអាពាហ៍ពិពាហ៍ជាមួយលោកតា គាំ អ៊ូ ក្នុងឆ្នាំថោះ គ.ស. ១៩៣៩។ លុះដល់ឆ្នាំខាល គ.ស. ១៩៨៦ លោកតា គាំ អ៊ូ និង លោកយាយ គឹម ហ៊ន់ បានប្រគល់ហូលនេះឲ្យមកលោក លុន ឆេងកៃ ក្នុងពេលចុះទៅធ្វើការស្រាវជ្រាវពិធីធ្វើហូលជាមួយ លី សុវីរ។*

*លោក លុន ឆេងកៃ និង នាងសា ណៃស៊ាង បានថតហូលនៅក្នុងគ.ស. ១៩៩៤ យកមកប្រគល់ឲ្យខ្ញុំតាមសំណូមពរ។*

*សូមបញ្ជាក់ថា ហូលនេះមានគោមល្អិតណាស់ ពិបាកធ្វើណាស់ ៖*

- *ពេលចងគាត គេវេញសរសៃសូត្រធ្វើជាចំណងគាត*
- *ពេលត្បាញ គេទាញសរសៃគាត ពិនិត្យឲ្យស្មើគោម ទើបទាញធ្មេញឈើគោះឲ្យជិតល្អ*
- *រយៈពេលត្បាញ ហូលមួយត្បាញ០១ខែ ឬជាង០១ខែ ទើបត្បាញហើយ (តាមចម្លើយពីចាស់ៗ)។*

*សូមបញ្ជាក់ថា មុនឆ្នាំ ១៩៨៦ ហូលនេះជាប្រដាប់សម្រាប់ខ្ចប់វត្ថុដទៃ បានជាមានសម្បុលស្រអាប់បែបនេះ។*

## ពណ៌ក្រហម

យោងតាមការសម្ភាសន៍ជាមួយអ្នកផលិត យើងបានរកឃើញថា ពណ៌ក្រហមត្រូវបានផលិតចេញពី »ល័ខក្រម៉« ។ សព្វថ្ងៃនេះ នៅក្នុងប្រទេសកម្ពុជាដំណើរការនៃការផលិតល័ខក្រម៉ ស្ទើរតែអស់ទៅហើយលើកលែងតែក្នុងខេត្តក្រចេះ នេះបើតាមសម្ដីលោកតា ថា ឈន អាយុ ៨០ ឆ្នាំ រស់នៅក្នុងភូមិ ត្រពាំងចំបក់ ឃុំសម្រាស់ពេន ស្រុកសំរោង ខេត្តតាកែវ ។ គាត់បានផលិតល័ខក្រម៉ជាង ៦០ ឆ្នាំហើយ ទោះបីជាក្នុងរបប ប៉ុល ពត ក៏ដោយ ។ គាត់ទើបតែឈប់ផលិតក្នុងឆ្នាំ ២០០៥ ពីព្រោះសុខភាព និងការបាត់បង់ដើមឈើអស់ជាច្រើនក្នុងតំបន់ដែលគាត់រស់នៅ។ ដើមឈើដែលផ្ដល់ទិន្នផលល័ខខ្ពស់ គឺដើមត្រាំង, ដើមសង្កែ, ដើមកកោះ, ដើមច័ន្ទគិរីជាដើម ។ ល័ខក្រម៉ភាគច្រើនដែលប្រជាជនប្រើសព្វថ្ងៃ គឺនាំចូលមកពីប្រទេសឡាវប្រមាណ ១០ តោន ក្នុង ០១ ឆ្នាំ ។

ដើម្បីទទួលបានពណ៌ក្រហម យើងត្រូវបំបែកល័ខជាដុំតូចៗ ហើយយើងរម្ងាស់រយៈពេល ០២ ម៉ោង បន្ទាប់មកយើងច្រោះ និងរក្សាទុកតែទឹកពណ៌ក្រហមសម្រាប់លាយជាមួយទឹកស្ទឹកអំពិល ដែលយើងបានរម្ងាស់ជាស្រេច ឧទាហរណ៍ប្រសិនបើយើងផលិតហូលមួយក្បិន (បណ្ដោយ ០៤ ម៉ែត្រ ទទឹង ០១ ម៉ែត្រ) យើងត្រូវការល័ខក្រម៉ ០១ គីឡូក្រាម (ប្រសិនបើសើម) និងស្ទឹកអំពិល ០១ គីឡូក្រាម ។ ការជ្រលក់ពណ៌នេះ យើងត្រូវការវត្ថុធាតុដើមនីមួយៗ ដែលអាចផលិតសារធាតុរាវចំនួន ០២ លិត្រ ក្នុងមួយមុខៗ ។ គួរកត់សម្គាល់ថាជាធម្មតា ទឹកម្ជូរដែលផលិតមកពីស្ទឹកអម្ពិលមានគុណភាពល្អជាងផ្លែ។

សូត្រសើមត្រូវបានជ្រលក់ពណ៌ក្រហមដោយបោក និងស្ងោរក្នុងទឹកនោះចំនួន ១០ នាទី ។ យើងត្រូវតែបោកវាយ៉ាងតិចណាស់ប្រាំបីដំណាក់កាលដើម្បីឲ្យពណ៌ចូលគ្រប់សរសៃសូត្រ ។ មួយដំណាក់កាលស្មើនឹង ១២០ ដង ។

នៅក្នុងដំណាក់កាល នេះពណ៌យើងទទួលបានក្រហមស្រាល ឬពណ៌ផ្ការឈូក ។ ពណ៌ក្រហមនឹងលេចឡើងកាន់តែច្បាស់បន្ទាប់ពីយើងបានជ្រលក់ពណ៌លឿង ។

## ពណ៌លឿង

ដើមឈើឈ្មោះថាប្រហូត ជាវត្ថុធាតុដើមដ៏សំខាន់ដើម្បីបង្កើតពណ៌លឿង ។ ដើមនោះអាចរកបាននៅតាមតំបន់ខ្ពង់រាបប្រទេសកម្ពុជា ។ គេចិញ្ច្រាំសម្បកវាជាដុំតូចៗ និងរម្ងាស់ប្រមាណកន្ទះ

ម៉ោង ។ បន្ទាប់មកយើងច្រោះវាយកតែទឹកពណ៌លឿង លាយជាមួយម្សៅសាជូវចំនួនមួយរយក្រាម ដែលនាំឲ្យទឹកនោះវានឹងបង្ហាញពណ៌លឿងស្រាល ។

ទឹកក្បុងត្រូវបានផលិតពីផេះសំបកផ្លែចេក គឺមានគុណភាពល្អប្រសើរជាងផេះដើមសង្កែ ឬក៏ដើមឈើផ្សេងទៀត ។ ផេះសម្បកចេក ០១ គីឡូក្រាម អាចផលិតទឹកក្បុងបាន ០៦ លីត្រ (ច្រោះរួចរាល់) ។ នៅក្នុងចំណុះនេះ យើងចែកជាបីផ្នែកហើយពីផ្នែក ត្រូវបានរក្សាទុកសម្រាប់ការលាងសូត្រ ឬឯផ្នែកដែលនៅសល់ទុកសម្រាប់ត្រាំគ្រាប់ជម្ពូ ។

ទឹកក្បុងអាចផលិតពីរុក្ខជាតិជាច្រើនដូចជា ផ្ទីបន្លា សម្បកផ្ទៃគ ឬ រុក្ខជាតិធម្មតាតែមិនសូវមានគុណភាពល្អ ។

ប្រសិនបើយើងចង់ទទួលពណ៌លឿងចាស់ យើងត្រូវការបន្ថែមពណ៌ពីគ្រាប់ជម្ពូដែលអាចរកទិញបានក្នុងទីផ្សារ ហើយយើងប្រើប្រាស់វាចំនួន ១៥០ ក្រាមសម្រាប់ហូល ០១ ក្បិន ។

យើងខ្ចប់គ្រាប់នេះទៅក្នុងកន្សែងរួចយកទៅត្រាំ ហើយនិងដុសវានៅក្នុងទឹកក្បុង ០២ លីត្រ បន្ទាប់មកយើងបោកសូត្រតាមធម្មតា ។ ក្រោយមកទៀតយើងស្ងោរសូត្រ ជាមួយទឹកព្រហូត ១៥ នាទីនោះសូត្រនឹងមានពណ៌លឿងចាស់ជាពុំខាន ។

## ពណ៌ខៀវ

សព្វថ្ងៃនេះការផលិតពណ៌ខៀវ គឺជាការពិបាកមួយជាងពណ៌ផ្សេងទៀតពីព្រោះបន្ទាប់ពីរបប ប៉ុល ពត មនុស្សដែលដឹងពីរបៀបផលិតស្លាប់ស្ទើរតែអស់ទៅហើយ ។ ករណីផ្សេងទៀតមកពីឥទ្ធិពលនៃសាកលភាវូបនីយកម្មជារួមដែលមានន័យថាពណ៌ខៀវ ដែលផលិតពីជាតុគីមីងាយស្រួលស្វែងរកនៅក្នុងទីផ្សារ ហើយថោកជាង ។ ដូច្នេះការប្រើផលិតសូត្រ ឬអំបោះពណ៌ខៀវពីពណ៌ធម្មជាតិមានការថយចុះយ៉ាងលឿន ហើយស្ទើរតែផុតរលត់អស់ទៅហើយ ។ តាមរយៈវិធីសាស្ត្រចាស់ យើងគ្រាន់តែអាចធ្វើបានពណ៌ស្រដៀងតែប៉ុណ្ណោះ ។

ជាប្រពៃណីយើងប្រើប្រាស់ដើមត្រុំ ដែលអាចរកបាននៅក្នុងភូមិ ឬក៏ដាំវា ។ យើងអាចប្រើប្រាស់ស្លឹកត្រុំ ដោយបុកវា ហើយពូតយកទឹកពណ៌បៃតង ឬត្រាំស្លឹកត្រុំស្រស់ពីរយប់ បន្ទាប់មកជ្រលក់នឹងសូត្រ ។ គុណភាពផលិតតាមវិធីនេះមិនសូវល្អ ពីព្រោះពណ៌នឹងហើរនៅក្នុងពេលខ្លីខាងមុខ ។

ដូច្នេះ យើងត្រូវការផលិតធ្ងះ ។ យើងត្រាំដើមត្រុំក្នុងទឹក០១យប់ បន្ទាប់មកយើងយកដើមត្រុំចេញ ទុកតែកាកសំណល់ និងទឹកដែលមានក្លិនអាក្រក់ ។ យើងបន្ថែមកំបោរលៀស និងស្ករត្នោតជារៀងរាល់ថ្ងៃរយៈពេល ០១ អាទិត្យ ឬយូរជាងនេះ ។ សារធាតុរាវនេះគេហៅថាធ្ងះ ដែលគេអាចជ្រលក់ពណ៌សូត្រ ឬអំបោះបាន ។ កាលពីមុនក្នុងដំបន់ ឬភូមិមួយ គ្រួសារនីមួយៗមានជំនាញរៀងៗខ្លួន។ គ្រួសារខ្លះអាចជាអ្នកត្បាញ ជាជាងឈើ និងអ្នកផ្សេងទៀត អាចជាអ្នកជ្រលក់ពណ៌ ។ ដំណើរការផលិតធ្ងះនេះ ពីមុនយ៉ាងហោចណាស់ក៏ប្រើរយៈពេល ០១ សប្តាហ៍ ដើម្បីធ្វើឲ្យរួចរាល់ ។

ក្នុងករណីត្រូវការប្រញាប់ពួកគេត្រូវតែផលិត មរ ដែលជាផ្នែកមួយនៃធ្ងះខាប់ ឬជាធម្មតាយើងហៅថាមេធ្ងះ ។ សារធាតុខាប់នេះ អាចរក្សាបានយូរដើម្បីលាយជាមួយធ្ងះថ្មី និងអាចជ្រលក់ពណ៌បានឆាប់ ។

## ពណ៌ខ្មៅ

ពណ៌នេះ គឺត្រូវបានគេចំរាញ់យកចេញពីសម្បកដើមអំពិលទឹក និងដើមធ័ត្រ ។ យើងបកយកសម្បកដើមឈើទាំងពីរនេះ ០២ គីឡូក្រាម នៃដើមឈើនីមួយៗបន្ទាប់មកយើងស្ងោរវា ០២ ម៉ោង ។ យើងច្រោះយកតែទឹក និងរក្សាសីតុណ្ហភាពរបស់វានៅធម្មតា បន្ទាប់មកយើងអាចជ្រលក់សូត្រ ហើយស្ងោរសូត្រម្តងទៀតជាមួយទឹកនេះ ។ក្រោយមកយើងបោកសូត្រជាមួយទឹកស្អិន ហើយហាលសម្ងួតវានៅក្នុងម្លប់ និងខ្យល់ យើងអាចទទួលបានសូត្រពណ៌ខ្មៅសម្រាប់ត្បាញ ។

ទឹកស្អិន គឺជាលទ្ធផលនៃប្រតិកម្មរវាងដែលច្រេះ ០១ គីឡូក្រាម ស្ករត្នោតមួយគីឡូក្រាម ក្រូចឆ្មារ ៣០ ផ្លែ និងទឹក ៣០ លីត្រ ។ សម្រាប់ក្រូចឆ្មារ យើងត្រូវការហាន់ជាចំណិតស្តើងៗ ។ ជារៀងរាល់ថ្ងៃ យើងត្រូវបន្ថែមចំណិតក្រូចឆ្មារជាលំដាប់ដើម្បីទទួលបានគុណភាពល្អប្រសើរនៃទឹកនេះ ។ យើងរក្សាទុកវត្ថុធាតុដើមទាំងនេះនៅក្នុងពាងធំមួយ និងក្រោមពន្លឺព្រះអាទិត្យពីចំនួន ០៥ ថ្ងៃ ទៅមួយសប្តាហ៍ ។ ក្នុងករណីខ្លះយើងអាចស្ងោរចំណិតតូចៗ នៃដើមគូលែនជាមួយនឹងដែករយៈពេល ០២ ម៉ោង ហើយយើងអាចជ្រលក់សូត្របាន ។ ធ្វើរបៀបនេះយើងថែមទាំងទទួលបានពណ៌ខ្មៅទៀតផង ។

ក្រៅអំពីរុក្ខជាតិដែលបានរៀបរាប់ខាងលើ គឺនៅមានរុក្ខជាតិផ្សេងៗទៀតដែលគេ អាចយកមកចម្រាញ់យកពណ៌បានដូចជា:

- ដូង (ស្រកី) ពណ៌ដូចស្រកីដូង

- *ខ្នុរ ពណ៌លឿងតិចៗ*
- *ននោង ពណ៌ខៀវខ្ចី*
- *ពោធិ៍ និងស្ដៅ ពណ៌លឿងចាស់ជាដើម ។*

***ហូល***

*គាធ គឺជាសំណុំសូត្រដែលគេចងសម្រាប់យកទៅជ្រលក់ពណ៌ ដែលភាសាអង់គ្លេស មានន័យថា អ៊ីខាត់ ។ ត្រង់នេះខ្មែរមានលក្ខណៈពិសេសរបស់ខ្លួនមួយ ។ គាធសសុទ្ធ ជាដំបូងគេ ត្រូវជ្រលក់នឹងពណ៌ក្រហម បន្ទាប់មកគេកាច់ចំណងពណ៌ក្រហមនេះ រួចហើយគេជ្រលក់នឹងពណ៌លឿង នឹងបន្តបន្ទាប់គឺពណ៌ខៀវ ។*

*ចំណងគាធ: កាលពីមុនយើងប្រើខ្សែដែលផលិតពីស្រទបចេកជ្វា ដែលពុំទាន់ចេញផ្លែ ។ គេច្រៀកស្រទបចេកនោះ រួចហាលថ្ងៃឲ្យស្រពាប់ទើបអាចចងបាន ។ សព្វថ្ងៃខ្សែដែលធ្វើពីនីឡុងត្រូវបានគេយកមកជំនួស ព្រោះតែកង្វះខាតដើមចេកប្រភេទនេះ ។ ម្យ៉ាងមកពីជំនឿប្រជាជនខ្មែរយើងដែលហាមមិនឲ្យដាំនៅក្បែរផ្ទះ ។ លើកលែងតែនៅក្នុងអង្គការខ្លះដូចជា វិទ្យាស្ថានវាយនភ័ណ្ឌប្រពៃណីខ្មែរ ដែលមានទីតាំងក្នុងខេត្តសៀមរាបជាដើមគឺនៅប្រើប្រាស់នៅឡើយ ។*

*ក្នុងប្រពៃណីខ្មែរមានក្បាច់គោមហូលច្រើនណាស់ ដែលកើតឡើងពីគំនិតច្នៃប្រឌិតផ្សេងៗពីក្បាច់គោមបុរាណរបស់សិប្បករយើងពីមួយជំនាន់ទៅមួយជំនាន់ ។ តាមការឲ្យដឹងពីអ្នកតម្បាញចាស់ៗបានឲ្យដឹងថា ក្នុងការធ្វើហូលមួយក្បិន គេត្រូវការរយៈពេលយូរណាស់ គឺយ៉ាងតិចបីខែ ព្រោះពួកគាត់ត្រូវចិញ្ចឹមដង្កូវ នាងដើម្បីផលិតសូត្រ ជ្រលក់ពណ៌ និងត្បាញដោយខ្លួនឯង ។ គួរកត់សម្គាល់ថា ក្បាច់គោមហូលពីបុរាណមានលក្ខណៈធំៗជាងសព្វថ្ងៃដូចជា ក្បាច់គោមធំ គោមខ្ទឹមច័ន្ទ គោមខ្សែរពីរជាន់ គោមភ្នែកគោជាដើម។ ការត្បាញហូលទាមទារឲ្យមានការព្យាយាមខ្ពស់ ។ អ្នកត្បាញត្រូវចេះតម្រឹមសរសៃសូត្រដើម្បីឲ្យលេចចេញជារូមគោមត្រង់ និងស្អាតល្អ ។*

***ផាមួង***

*ជាប្រភេទមួយនៃសំពត់ខ្មែរយើង ហើយមានច្រើនពណ៌ទៅតាមតម្រូវការ ។ ផាមួងភាគច្រើន គឺមានពណ៌តែមួយ ។ យើងនៅចាំបានថាកាលពីប៉ុន្មានឆ្នាំមុន ផាមួងកទា មានន័យថា ពណ៌ដូចកនៃសត្វទាមានការពេញនិយមខ្លាំងណាស់ក្នុងចំណោមអ្នកប្រើប្រាស់ ។*

តាមធម្មតាគេត្បាញផាមួងដោយប្រើថ្នរចំនួន០៣ យ៉ាងតិច តែអាចច្រើនជាងនេះក្នុងករណី ដែលផលិតករចង់រចនាបន្ថែមនូវ ជរដើង ផ្កា ឬក្បាច់ផ្សេងៗ ។ នៅកោះដាច់មានត្បាញ រហូតដល់ថ្នរចំនួន ៣០ ។ ផាមួងនេះគេឲ្យឈ្មោះថា ផាមួងត្បូងពេជ្រ ដែលកំពុងតែមានភាពល្បីល្បាញ។

## ចរបាប់

តាមការអង្កេតសព្វថ្ងៃ តំបន់ដែលនៅផលិតចរបាប់នេះគឺនៅក្នុង ឃុំព្រែកលួង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។ គេប្រើប្រាស់ចរបាប់ គឺសម្រាប់កាត់សម្លៀកបំពាក់ប្រពៃណីក្នុងមង្គលការ និងពិធីមង្គលផ្សេងៗ។ របៀបនៃការត្បាញចរបាប់នេះ គឺប្រហែលនឹងការត្បាញផាមួង ឬហូលដែរ ។ ចរបាប់មានក្បាច់ផ្កាផ្សេងៗ ដូចជា ផ្កាថ្កុល ផ្កាកន្ទួត ផ្កាច័ន្ទ ត្បូងពេជ្រ ជាដើម ។ មានប្រភេទសំពត់ដែលស្រដៀងនឹងចរបាប់គឺល្បើក ។ ល្បើកខុសពីចរបាប់ត្រង់ក្នុងចរបាប់ ផ្កាដែលគេពន្ទេចឡើងគឺគេប្រើសៃសយ ឯល្បើកវិញគេពន្ទេចដោយប្រើសូត្រ ។ ចរបាប់ មានថ្នរច្រើនដែលអ្នកត្បាញខ្លះបានប្រាប់យើងថាមានរហូតដល់ទៅ ៦០ ថ្នរ។

## សារុងសូត្រ

សារុងសូត្រ ជាសំពត់មួយប្រភេទដែលជនជាតិខ្មែរឥស្លាមនិយមចូលចិត្តប្រើ និងស្លៀកពាក់ចូលរួមក្នុងពិធីធំៗទៀតផង ។ ធម្មតាសារុងសូត្រមិនមានក្បាច់ ឬគោមអ្វីស្មុគស្មាញទេ តាមរយៈការត្បាញកន្ទងមក ។ សារុងសូត្រមានគោមដុំអាចម៍ផ្កា ដែលមានភាពល្បីគួរសម និងសារុងសូត្រសជាដើម។

## ក្រមាសូត្រ

ក្រមាសូត្រ ប្រើសម្រាប់បង់ចូលរួមក្នុងពិធីផ្សេងៗ ។ ជាទូទៅប្រជាជនកម្ពុជាមានក្រមាប្រើប្រាស់យ៉ាងហោចណាស់មួយ ដែលស្ទើរតែទាំងអស់ធ្វើពីអំបោះសុទ្ធ ឬអំបោះលាយសូត្រ ។ ការប្រើប្រាស់ក្រមារជាទម្លាប់មួយនៃប្រជាជនយើង ។ ការត្បាញក្រមា និងសារុងសូត្រ គេប្រើតែថ្នរពីរ និងលឿនជាងការត្បាញហូល ឬចរបាប់ ។

**ពិដាន និងរនាំង**

ពិដានត្រូវបានគេប្រើសម្រាប់តែក្នុងពិធីសាសនា ។ គោមដែលមាននៅលើពិដានមាននិយាយរៀបរាប់ពីពុទ្ធប្រវត្តិ ធម្មជាតិ ផ្កា សត្វហង្ស រូបស្រីអប្សរាជាដើម ។

វិធីសាស្ត្រនៃការធ្វើពិដាន គឺស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងការធ្វើហូលព្រោះគេត្រូវយកសូត្រមកចងគាជ នឹងជ្រលក់ពណ៌ដូចគ្នាទៅនឹងដំណាក់កាលទាំងឡាយនៃការធ្វើហូល ។ សព្វថ្ងៃពិដានមានធ្វើនៅក្នុងស្រុកបាទី។

រនាំងជាសិល្បៈតម្បាញដែលគេត្បាញជារឿងពុទ្ធប្រវត្តិ ឬជារូបសត្វ ផ្កាភ្ញី សម្រាប់ដាក់តាំងព្យួរបញ្ឈរនៅជាប់ជញ្ជាំងព្រះវិហារ ឬសម្រាប់លម្អគេហដ្ឋាន។

រនាំងគេអាចមូរដូចជាព្រះបទបាន តែពេលខ្លះគេអាចបត់វាជាផ្នត់ដូចសំពត់បានដែល ដើម្បីថែរក្សាទុក។ រូបភាពផ្សេងៗនៃផ្ទាំងរនាំងនិមួយៗច្រើនរំលេចជារូបសត្វ ឬដើមឈើ ផ្កាភ្ញី ដដែលៗមួយគូរៗតម្រៀបគ្នាជាជាន់ថ្នាក់តិច ឬច្រើនទៅតាមការចង់បានរបស់អ្នកត្បាញ និងអ្នកបញ្ជាទិញ។



ពិតានក្បាច់ផ្កា



ពិតានរូបសត្វ ផ្សេងៗ



ក្បាច់លម្អជើងពិតាន

ក្បាច់លម្អដើងពិតាន



ពិតានរូបសត្វ ផ្សេងៗ



ក្បាច់លម្អជើងពិតាន



រនាំងហូលរូបសំពៅ នាគ ក្រពើ ផ្ទះ



រនាំងហូលរូបសំពៅ នាគ ក្រពើ ផ្ទះ



នៅាំងហូលរូបសំពៅ នាគ ក្រពើ ផ្ទះ



នៅាំងរូបសត្វ និងផ្កាចាន់



ពិតាន ឬរនាំងរឿងពុទ្ធប្រវត្តិ



ពិតាន ឬរនាំងរឿងពុទ្ធប្រវត្តិ



ពិតាន ឬរនាំងរឿងពុទ្ធប្រវត្តិ



រូបភាពពុទ្ធប្រវត្តិព្រះសត្តទ្ធយាងចេញទៅបួស



ពិតានរឿងពុទ្ធប្រវត្តិ



ពិតានរឿងពុទ្ធប្រវត្តិ



ពិតានរឿងពុទ្ធប្រវត្តិ



រូបភាពលំអិត កាលព្រះពុទ្ធទ្រង់ផ្ចាញ់មារ



ព្រះពុទ្ធទ្រង់ផ្ចាញ់មារ



ព្រះសត្តទ្តយាងចេញសាងព្រះផ្នួស



ស្ដេចចតុមហារាជទ្រដើងសេះ



រូបព្រះពុទ្ធរូបទ្រង់ឈរ



យក្សជិះលើដំរី (ផ្កាញ់មារ)



ប្រោសពុទ្ធបិតា



ក្បាច់លម្អជរជើងពិតានហូល



រឿងពុទ្ធប្រវត្តិ



រឿងពុទ្ធប្រវត្តិ



រនាំងរូបក្បាច់ផ្កាចាន់លម្អដោយសត្វនាគ



រនាំងរូបក្បាច់ផ្កាចាន់លម្អដោយសត្វនាគ



រូបភាពលំអិត



រូបភាពលំអិត ការរចនាក្បាច់



ទម្រង់ក្បាច់រចនាជារូបភាពសត្វ និងរុក្ខជាតិផ្សេងៗ



រនាំផលម្អដោយរូបសត្វផ្សេងៗ



រនាំផលម្អដោយរូបសត្វផ្សេងៗ



*រូបភាពលំអិតអំពីរនាំងរូបនាគ សេះ និងក្បាច់ជរជើងលម្អ*



រនាំងរូបសំពៅ ទេសភាព (សត្វផ្សេងៗ និងដើមឈើ)



រនាំងរូបសំពៅ ទេសភាព (សត្វផ្សេងៗ និងដើមឈើ)



*រូបភាពលំអិត ក្បាច់លម្អ សត្វនាគ ក្រសា កុក ត្រី គោ សំពៅ*



ក្បាច់ផរដើងប្រកបដោយការរចនាយ៉ាងប្រសប់



ក្បាច់ផរដើងប្រកបដោយការរចនាយ៉ាងប្រសប់



ក្បាច់ផ្កាចាន់លម្អជើងជរ





រនាំងរូបនាគ



ទោំងឬពិតាន រឿងព្រះវេស្សន្តរជាត្តក



រូបភាពលំអិត រឿងព្រះវេស្សន្តរ



រូបភាពលំអិត រឿងព្រះវេស្សន្តរ



រនាំងរូបក្ងោកនិងផ្កា



រនាំងរូបក្ងោកនិងផ្កា



រនាំងរូបប្រាសាទ រុក្ខជាតិនិងសត្វ

រូបភាពលំអិត



រូបភាពលំអិត



រូបភាពទេវកថា កូរសមុទ្រទឹកដោះ



រនាំងរូបទេសភាព



រូបភាពលំអិតទូក និងបរិស្ថានធម្មជាតិ



រូបភាពជីវិតនិងធម្មជាតិ



រូបភាពជីវិតនិងធម្មជាតិ



ពិតានឬរនាំងការយាងចេញសាងព្រះផ្នួសរបស់ព្រះសម្មាសម្ពុទ្ធ (កាលមិនទាន់បានត្រាស់)



ពិតានឬរនាំងការយាងចេញសាងព្រះផ្នួសរបស់ព្រះសម្មាសម្ពុទ្ធ (កាលមិនទាន់បានត្រាស់)



ពិតាន ឬរនាំងរឿងព្រះវេស្សន្តរ



*រូបភាពលំអិត តាជូជក*



ការរចនារូបភាពផ្កាភ្ញីលើពិតាន ឬរនាំង





ការរចនារូបភាពផ្កាភ្ញីលើពិតាន ឬរនាំង



រូបភាពលំអិតស្តីអំពីការរចនាលើរនាំង ឬពិតាន



ពិតានក្បាច់ផ្កាចាន់



ពិតានក្បាច់ផ្កាចាន់



ពិតានរូបភាពផ្សេងៗ



រូបភាពលំអិត ពិតានរូបភាពផ្សេងៗ



រូបភាពទេសភាពផ្សេងៗនិងសំពៅ



រូបភាពទេសភាពផ្សេងៗនិងសំពៅ



រូបភាពទេសភាពផ្សេងៗនិងសំពៅ

រូបភាពលំអិត



ពិតានរូបភាពផ្សេងៗ



រូបភាពលំអិត



ពិតានក្បាច់ផ្កាចាន់ លំអដវរដើផ



ពិតានក្បាច់ផ្កាចាន់



រូបភាពលំអិត ពិតានក្បាច់ផ្កាចាន់





ទិដ្ឋភាពសាលាឆាន់វត្តអង្គអណ្តែត ស្រុកព្រៃកប្បាស ខេត្តតាកែវ



ពិតានរឿងពុទ្ធប្រវត្តិ ដែលបានអាយុកាលយូរ កំពុងទទួលរងភាពទ្រុឌទ្រោម



ពិតានចាស់ នៅវត្តអង្គអណ្តែត



ពិតានចាស់ នៅវត្តអង្គអណ្តែត



ពិតានចាស់ នៅវត្តអង្គអណ្ដែត



រនាំងដែលបានលម្អទៅដោយរូបផ្កា





ពិតានរឿងពុទ្ធប្រវត្តិ





ពិតានរឿងពុទ្ធប្រវត្តិ



ពិតានរឿងពុទ្ធប្រវត្តិ



ពិតានរឿងពុទ្ធប្រវត្តិ



ពិតានលម្អទៅដោយរូបភាពផ្សេងៗ



ពិតាន រូបភាពផ្សេងៗ





ពិតានរឿងពុទ្ធប្រវត្តិ



ពិតានរឿងពុទ្ធប្រវត្តិ



ពិតានរឿងពុទ្ធប្រវត្តិ



ពិតានរឿងពុទ្ធប្រវត្តិ



ពិតានរឿងពុទ្ធប្រវត្តិ



ក្បាច់របចនាលម្អដើផពិតាន



រូបភាពលំអិតក្បាច់លម្អ





ក្បាច់ផ្កាចាន់លម្អលើរនាំង



សរសៃសូត្រចងគៀត



ការចងគៀត



រូបស្ត្រីកំពុងត្បាញពិតានរឿងពុទ្ធប្រវត្តិ

